កាន់តែទុកចិត្ត កាន់តែចំរើន

# ហត្ថាកសិករ លីមីតធីត

**HATTHA KAKSEKAR LIMITED**




# របាយការណ៍ប្រចាំឆ្នាំ

# ២០១៤


សេវាធនាគារចល័ត

# ប្រតិបត្តិការសំខាន់ៗ



| ប្រតិបត្តិការសំខាន់ៗ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|
| ចំនួនខេត្ត-ក្រុងប្រតិបត្តិការ | ២៤ | ២៤ | ២៥ |
| ចំនួនស្រុកប្រតិបត្តិការ | ១៨៩ | ១៨៨ | ១៩១ |
| ចំនួនឃុំប្រតិបត្តិការ | ១,២៣៦ | ១,៤៥៦ | ១,៥៧៤ |
| ចំនួនភូមិប្រតិបត្តិការ | ៧,៤៩៩ | ៨,៨៣២ | ៩,៨៥២ |
| ចំនួនការិយាល័យប្រតិបត្តិការ | ១២១ | ១៣៦ | ១៤២ |
| ចំនួនម៉ាស៊ីនអេធីអឹម | ១៥ | ៣៧ | ៧២ |
| ចំនួនបុគ្គលិកសរុប | ១,២៧៨ | ១,៦១៣ | ១,៩១១ |
| ផលិតភាពបុគ្គលិក ( CO ) | ១៧៤,៥៩៨ | ២០៦,៣២៨ | ៣០៦,២៣៣ |
| ទំហំឥណទានមធ្យម | ១,៣៧៩ | ១,៧៤៦ | ២,៤៨៦ |
| ឥណទានមានហានិភ័យ ( PAR % ) | ០.១២% | ០.០៦% | ០.០៣% |
| ចំនួនអតិថិជនខ្ចីប្រាក់សរុប | ៧៤,៥៥៩ | ៨៣,៤១៦ | ១០០,៦៣៦ |
| សមតុល្យឥណទានសរុប | ១០១,៧៨៣,១៥៩ | ១៤៤,១៩៤,៥៧០ | ២៤៩,៦៨០,២៥២ |
| ចំនួនអតិថិជនប្រាក់បញ្ញើសន្សំសរុប | ១០៨,០៣៧ | ១៤៣,៥១៩ | ១៩០,៦៥២ |
| សមតុល្យប្រាក់បញ្ញើសរុប | ៤៤,២៥៤,៩៧០ | ៨២,៤៧៣,៥៧៥ | ១៧២,៣៣៣,៣៥២ |
| **ទ្រព្យសកម្មសរុប** | **១២២,៩៧២,៨៦៥** | **១៧៩,៥៧២,៦៨៦** | **៣១៦,៣៦៣,៨០៥** |

# របាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ

| របាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ និងក្នុងធនាគារ | ១៤,២៧៩,៩២៧ | ២៧,៣០៣,៧០៦ | ៥៦,២៦៦,១៨៦ |
| ចំនួនប្រាក់កម្ចីក្នុងដៃអតិថិជន | ១០១,៧៨៣,១៥៩ | ១៤៤,១៩៤,៥៧០ | ២៤៩,៦៨០,២៥២ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ២,៥៣២,៤៦៣ | ៣,២៧៣,២៧៧ | ៤,៣១១,០២៤ |
| ទ្រព្យសកម្មអរូបិយ | ១,៩៣៣,៦២៤ | ១,៥៧៤,៤៨៦ | ១,១៦៣,៣១១ |
| ទ្រព្យសកម្មផ្សេងៗ | ២,៤៤៣,៦៩២ | ៣,២២៦,៦៤៧ | ៤,៩៤៣,០៣២ |
| **ទ្រព្យសកម្មសរុប** | **១២២,៩៧២,៨៦៥** | **១៧៩,៥៧២,៦៨៦** | **៣១៦,៣៦៣,៨០៥** |
| **ទ្រព្យអកម្ម** | | | |
| ប្រាក់បញ្ញើ-សន្សំរបស់អតិថិជន | ៤៤,២៥៤,៩៧០ | ៨២,៤៧៣,៥៧៥ | ១៧២,៣៣៣,៣៥២ |
| សាច់ប្រាក់ជំពាក់ភាគទុនិក | ៥២,៥៣៧,៦៧៧ | ៦៦,៦៥៩,៩៤៧ | ៩៥,៦១៥,៧៤៨ |
| បុព្វលាភភាគហ៊ុន | ៦២៩,២៩៥ | ៩១២,៥១៨ | ១,២៨៥,២០៨ |
| សំវិធានធនលើពន្ធប្រាក់ចំណូល | ៥៦១,៦៨១ | ៨៤២,១៨២ | ១,៧៦០,២២៩ |
| ទ្រព្យអកម្មផ្សេងៗ | ៣,១០២,១៨៤ | ៣,៤២១,០៨៦ | ៦,៦២៤,៥៥៣ |
| **ទ្រព្យអកម្មសរុប** | **១០១,០៨៥,៨០៧** | **១៥៤,៣០៩,៣០៨** | **២៧៧,៦១៩,០៩០** |
| **មូលធនភាគទុនិក** | | | |
| មូលធនស្អួល | ២១,១៥៧,៧៣៩ | ២៤,៥៣៤,០៥៩ | ៣៨,០១៥,៣៩៦ |
| អនុបំណុលដែលមានស្រាប់ | ៧២៩,៣១៩ | ៧២៩,៣១៩ | ៧២៩,៣១៩ |
| **មូលធនភាគទុននិកសរុប** | **២១,៨៨៧,០៥៨** | **២៥,២៦៣,៣៧៨** | **៣៨,៧៤៤,៧១៥** |
| **ចំណូល និងចំណាយ** | | | |
| ចំណូលការប្រាក់ | ២៣,២០០,៦៣០ | ៣០,០៣៥,២៣៩ | ៤៥,៤៩៦,៨០១ |
| ចំណាយការប្រាក់ | (៦,៥៧៤,៦០១) | (៩,៥៥៦,៣០៥) | (១៦,៨៨១,២៨៦) |
| ចំណូលបានមកពីការវិនិយោគផ្សេងៗ | ៧៤០,១៨៤ | ៤៨០,៩១៦ | ២៨២,២១៨ |
| ចំណាយលើរដ្ឋបាលទូទៅ | (១១,៦៨៤,៩១៣) | (១៥,០៩៣,០៣១) | (១៩,៦០៩,៣៦២) |
| សំវិធានធនទៅលើឥណទានខូច និងសង្ស័យ | (៣១៥,០៦៨) | (៥១០,៩២៨) | ៩១១,៨៩៧ |
| សាច់ប្រាក់សុទ្ធមុនពេលបង់ពន្ធ | (៩៤៧,៨៥៩) | (១,០៩៥,៨៩៦) | (២,០៧៨,៣៣៣) |
| **សាច់ប្រាក់សុទ្ធចំណេញប្រចាំឆ្នាំ** | **៤,៤១៨,៣៧៣** | **៤,២៥៩,៩៩៥** | **៨,១២១,៩៣៥** |

# សកម្មភាពសង្ខេបសង្ខេប

| សកម្មភាពសង្ខេបសង្ខេប | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|
| **ទំនួលខុសត្រូវដល់អតិថិជន** | | | |
| អតិថិជនកម្ចីជាស្ត្រី | ៧៦% | ៧០% | ៧០% |
| ដែនគ្របដណ្តប់ជនបទនៃអ្នកខ្ចីប្រាក់ | ៨០% | ៧៩% | ៨១% |
| អត្រាថែរក្សាអតិថិជន | ៧៨% | ៧៧% | ៨១% |
| អត្រាអតិថិជនដែលមានប្រាក់ចំណូលទាបជាង ២.៥ដុល្លារក្នុង១ថ្ងៃ | ៣១% | ២៩% | ២៩% |
| ការត្រួតពិនិត្យប្រវត្តិខ្ចីប្រាក់តាម CBC | ១០០% | ១០០% | ១០០% |
| កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ (ចំនួនអតិថិជន) | ១៣៩ | ៣០៤ | ៣០៩ |
| ធានារ៉ាប់រងខ្នាតតូច (ចំនួនអ្នកខ្ចីប្រាក់) | - | - | ១,១១១ |
| **ទំនួលខុសត្រូវដល់បុគ្គលិក** | | | |
| បុគ្គលិកនារី | ២៤.៨៨% | ២៦.៨៤% | ២៧.៨៤% |
| អត្រាថែរក្សាបុគ្គលិក | ៩៣.៥១% | ៩៣.៣០% | ៩០.៧៤% |
| ចំនួនវគ្គបណ្តុះបណ្តាលសំរាប់បុគ្គលិកម្នាក់ | ៥ | ៩ | ៧ |
| **ទំនួលខុសត្រូវដល់រដ្ឋាភិបាល (ដុល្លារ)** | | | |
| ការបង់ពន្ធលើប្រាក់ចំណេញ | ២៣៨,៣០៥ | ៣០៧,៤០៨ | ៤៥៥,១០០ |
| ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម | ៣៥១,៦៥៦ | ៤៤៣,៨៥៥ | ៥៦១,៧៤៤ |
| ពន្ធកាត់ទុក | ១,០១៦,៤២៤ | ១,៣៤៥,៧៣៩ | ១,៧៤៥,៤០១ |
| ពន្ធប្រចាំឆ្នាំដែលទទួលបានមកវិញ | ៦៤១,៥៨៦ | ៨១៥,០៣៦ | ១,៧៣៤,១៧២ |
| **សរុប** | **២,២៤៧,៩៧១** | **២,៩១២,០៣៨** | **៤,៤៩៦,៤១៧** |

* តួលេខខាងលើ ហត្ថាកសិករ លីមីតធីត បង្ហាញតែចំនួនដែលបានបង់ប្រាក់ទៅអគ្គនាយកដ្ឋានពន្ធដារតែប៉ុណ្ណោះ។

# សូចនាករសេដ្ឋកិច្ចកម្ពុជា

| សូចនាករសេដ្ឋកិច្ចសំខាន់ៗ | ២០១២ | ២០១៣ (ប) | ២០១៤ (ព) | ២០១៥ (ព) | ២០១៦ (ព) |
|---|---|---|---|---|---|
| **កំណើន និងតម្លៃប្រើប្រាស់** | | | | | |
| ផសស ជាក់ស្តែង(% ផ្លាស់ប្តូរប្រចាំឆ្នាំ) | ៧.៣ | ៧.៤ | ៧.២ | ៧.៥ | ៧.២ |
| ផសស តិចតួច (ជាលានដុល្លារ) | ១៤,១៨៨ | ១៥,៣៧៣ | ១៦,៣៦៧ | ១៧,៧៥៩ | ១៩,១៧៣ |
| សន្ទស្សន៍តម្លៃប្រើប្រាស់(% ផ្លាស់ប្តូរប្រចាំឆ្នាំ) | ២.៥ | ៤.៦ | ៥.០ | ៥.៥ | ៦.០ |
| **វិស័យសាធារណៈ** | | | | | |
| ចំណូលរបស់រដ្ឋាភិបាល(%នៃផសស) | ១៥.៣ | ១៥.១ | ១៦.១ | ១៦.៤ | ១៦.៤ |
| ចំណាយរបស់រដ្ឋាភិបាល (%នៃផសស) | ២១.០ | ២១.៥ | ២០.៤ | ២០.៩ | ២១.៣ |
| សមតុល្យសរុបរបស់រដ្ឋាភិបាល លើកលែងប្រាក់កម្ចី (%នៃផសស) | -៥.៧ | -៦.៤ | -៤.៣ | -៤.៥ | -៤.៩ |
| សមតុល្យសរុបរបស់រដ្ឋាភិបាល រួមបញ្ចូលប្រាក់កម្ចី (%នៃផសស) | -៣.៣ | -២.៧ | -២.៥ | -៣.៥ | -៣.៣ |
| **ពាណិជ្ជកម្មបរទេស និងការវិនិយោគ** | | | | | |
| តុល្យការពាណិជ្ជកម្ម (ជាលានដុល្លារ) | -២,៤៥៦ | -២,៥៩៨ | -២,៩០៨ | -២,៩៥៦ | -២,៨៥៦ |
| កំណើននាំចេញទំនិញ | ៥,៦៣៣ | ៦,៨៩០ | ៨,១៩៣ | ៩,៧០០ | ១១,៥៧២ |
| % ផ្លាស់ប្តូរប្រចាំឆ្នាំ | ៧.៩ | ២២.៣ | ១៨.៩ | ១៨.៤ | ១៩.៣ |
| កំណើននាំចូលទំនិញ | ៨,០៨៩ | ៩,៤៨៩ | ១១,១០២ | ១២,៦៥៦ | ១៤,៤២៨ |
| % ផ្លាស់ប្តូរប្រចាំឆ្នាំ | ២០.៦ | ១៧.៣ | ១៧.០ | ១៤.០ | ១៤.០ |
| ការវិនិយោគដោយផ្ទាល់ពីបរទេស (ជាលានដុល្លារ) | ១,៤០៥ | ១,២៩៩ | ១,៣៨០ | ១,៤០០ | ១,៤៥០ |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | |
| ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ (% ផ្លាស់ប្តូរប្រចាំឆ្នាំ) | ២៩.៧ | ១២.២ | ២១.៣ | N.A | N.A |
| ប្រាក់កម្ចីក្នុងប្រព័ន្ធធនាគារ (% ផ្លាស់ប្តូរប្រចាំឆ្នាំ) | ៣៥.១ | ២៥.២ | ១៦.២ | N.A | N.A |
| ប្រាក់បញ្ញើដល់ ផសស (% ផ្លាស់ប្តូរប្រចាំឆ្នាំ) | ៤៧.៣ | ៤៩ | ៥៣ | N.A | N.A |
| ប្រាក់កម្ចីដល់ ផសស (% ផ្លាស់ប្តូរប្រចាំឆ្នាំ) | ៤១ | ៤៩.៨ | ៥០ | N.A | N.A |
| អត្រាប្តូរប្រាក់រវាងប្រាក់រៀល/ដុល្លារ (ការព្យាករណ៍) | ៣,៩៩៥.០ | ៣,៩៩៥.០ | ៤,០៦៥ | ៤,០៧៦ | ៤,០៥០ |

ប្រភព៖ ប្រភពទិន្នន័យជាតិ, *IMF* និងការព្យាករណ៍បុគ្គលិកធនាគារពិភពលោក

ប = ប៉ាន់ស្មាន

ព = ព្យាករណ៍

គ = គំរោង

# មាតិកា

## ០១ ព័ត៌មានទូទៅរបស់ហត្ថាកសិករ


| | |
|---|---|
| ចក្ខុវិស័យ និងបេសកកម្ម | ០១ |
| ប្រវត្តិហត្ថាកសិករ លីមីតធីត | ០២ |
| សាររបស់ប្រធានក្រុមប្រឹក្សាភិបាល | ០៤ |
| សាររបស់ប្រធានអគ្គនាយក | ០៦ |


## ០២ ទិដ្ឋភាពលើសកម្មភាពអាជីវកម្ម


| | |
|---|---|
| រចនាសម្ព័ន្ធមូលធនសាជីវកម្ម | ០៩ |
| រចនាសម្ព័ន្ធស្ថាប័ន | ១៣ |
| ក្រុមប្រឹក្សាភិបាល | ១៤ |
| គណៈគ្រប់គ្រង | ១៧ |
| ព័ត៌មានអតិថិជន | ២៦ |
| ចំណែកទីផ្សារ | ២៧ |
| ផលិតផល និងសេវាកម្ម | ២៨ |
| ធនធានមនុស្ស | ៣៥ |
| សង្គម និងបរិស្ថាន | ៣៧ |
| ហានិភ័យ និងប្រតិបត្តិតាម | ៤០ |


## ០៣ របាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ


| | |
|---|---|
| របាយការណ៍សវនកម្មឯករាជ្យ | ៤១ |
| របាយការណ៍ហិរញ្ញវត្ថុ | ៤៣ |


## ០៤ ព័ត៌មានផ្សេងៗ


| | |
|---|---|
| ពានរង្វាន់ ការវាយតម្លៃ និងដៃគូវិនិយោគ | ៤៧ |
| ការិយាល័យប្រតិបត្តិការ | ៤៩ |
| អាសយដ្ឋាន | ៥០ |

# ចក្ខុវិស័យ

ជាគ្រឹះស្ថានផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេ និងមាននិរន្តរភាពក្នុងការជួយអតិថិជនឲ្យទទួលបានជោគជ័យក្នុងអាជីវកម្ម តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុដ៏សមស្របដើម្បីរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា។

# បេសកកម្ម

ហត្ថាកសិករខិតខំរក្សានិរន្តរភាពយូរអង្វែងផ្នែកហិរញ្ញវត្ថុ និងសង្គមដោយធ្វើឲ្យប្រាក់ចំណូលរបស់អតិថិជនកាន់តែ ប្រសើរឡើង។ ហត្ថាកសិករ ផ្តល់សេវាកម្មឥណទាន ប្រាក់សន្សំ និងសេវាហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត ជាពិសេសផ្តល់ជូនអតិថិជនជាស្ត្រី និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅតាមជនបទទូទាំងប្រទេសកម្ពុជា។

# ប្រវត្តិ ហត្ថាកសិករ លីមីតធីត

**១៩៩៤** គំរោងសន្និសុខស្បៀងមួយដែលត្រូវបានបង្កើតឡើងដោយOCSD/OXFAM-Quebecដែលជាអង្គការរបស់ប្រទេសកាណាដា បានផ្តល់ឥណទានខ្នាតតូចបំផុតដល់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទក្នុងឃុំចំនួន ៤ នៃខេត្តពោធិសាត់។

**១៩៩៦** គំរោងសន្និសុខស្បៀងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានគេផ្តល់ឈ្មោះថា ហត្ថាកសិករ ដែលមានន័យថា ដៃរបស់កសិករ ឬជាដៃសំរាប់ជួយកសិករ ។ នៅពេលនោះ ការិយាល័យកណ្តាលរបស់អង្គការ ហត្ថាកសិករ គឺស្ថិតនៅក្នុងខេត្តពោធិ៍សាត់។

**២០០១** អង្គការហត្ថាកសិករ បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដោយមានដើមទុនសរុបចំនួន ៧៧.៨៥០ដុល្លារអាមេរិក ដោយផ្លាស់ប្តូរស្ថានភាពរបស់ស្ថានប័នពីអង្គការក្រៅរដ្ឋាភិបាលទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវ មានកំរិត ដែលមានឈ្មោះថ្មីហៅថាហត្ថាកសិករ លីមីតធីត។ នៅក្នុងពេលជាមួយគ្នានោះដែរ ហត្ថាកសិករ លីមីតធីត បានទទួលអាជ្ញាប័ណ្ណរយៈពេល៣ឆ្នាំពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការសេវាកម្ម មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

**២០០៣** ហត្ថាកសិករបានបង្កើនទុនវិនិយោគពី១៨០.០០០ទៅ២៥៧.៨៥០ដុល្លារអាមេរិកដោយនេះបានមកពីការវិនិយោគរបស់ស្ថាប័ន CORDAID ដែលមានមូលដ្ឋាននៅប្រទេសហូឡង់ ។ CORDAID គឺជាភាគទុននិកទី៥ ដែលមានភាគហ៊ុនចំនួន១៩% នៃភាគហ៊ុនសរុបនៅហត្ថាកសិករ បន្ថែមទៅលើភាគទុននិកដែល មានស្រាប់នៅពេលនោះរួមមាន អង្គការហត្ថាកសិករសមាគមបុគ្គលិកហត្ថាកសិករ SIDI និង ភាគទុនិកឯកជន។

**២០០៧** សេវាកម្មប្រាក់បញ្ញើសន្សំ និងប្រព័ន្ធព័ត៌មានវិទ្យាសំរាប់បំរើឲ្យសេវាកម្មនេះ ត្រូវបានគេដាក់ឲ្យប្រើប្រាស់ដើម្បីត្រួតពិនិត្យនិងគ្រប់គ្រងលើប្រតិបត្តិការ។ ទន្ទឹមនឹងគ្នានោះដែរហត្ថាកសិករបានបង្កើនដើមទុនរបស់ខ្លួនពី ២៥៧.៨៥០ រហូតដល់ ១.៣៣៩.៧០០ដុល្លារអាមេរិក។ ដោយសារតែ ហត្ថាកសិករមាននិរន្តរភាព ផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ និងអភិបាលកិច្ចល្អធនាគារជាតិនៃកម្ពុជាក៏បានផ្តល់អាជ្ញាប័ណ្ណគ្មានកាលកំនត់ សំរាប់ប្រតិបត្តិការ សេវាមីក្រូហិរញ្ញវត្ថុដល់ហត្ថាកសិករ ។

**២០០៨** ដើម្បីឆ្លើយតបទៅនឹងការរីកចំរើនរបស់ខ្លួនហត្ថាកសិករបានសំរេចបង្កើនដើមទុនរបស់ខ្លួនបន្ថែមរហូតដល់២.៧លានដុល្លារអាមេរិក ដោយមានការចូលរួមពីភាគទុនិកថ្មីចំនួន ៣ ស្ថាប័នបន្ថែមទៀតគឺ អូកូគ្រេឌីត ន័រហ្វាន់ និងទ្រីបផលហ្សាម ។

**២០១០** ដោយសារតែ ហត្ថាកសិករ មាននិរន្តរភាពផ្នែកប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើសន្សំពីសាធារណៈជន ( MDI-License ) ដល់ហត្ថាកសិករ លីមីតធីត។ ការទទួលអជ្ញាប័ណ្ណនេះសរបញ្ជាក់ឲ្យឃើញពីភាពជោគជ័យមួយក្នុងចំណោមភាពជោគជ័យជាច្រើនរបស់ ហត្ថាកសិករ លើការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជនពិសេសអនុញ្ញាតឲ្យហត្ថាកសិករ កេណ្ឌប្រមូលប្រាក់ សន្សំពីសាធារណៈជនជាផ្លូវការ។ លើសពីនេះផ្នែកព័ត៌មានវិទ្យាបាន នឹងកំពុងសិក្សាលើការបំពាក់ឲ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនាគារថ្មី ដើម្បីធ្វើយ៉ាងណាឲ្យការបំរើសេវាកម្មអតិថិជន និងសកម្មភាពប្រតិបត្តិការ កាន់តែមានប្រសិទ្ធភាពថែមទៀត ដែលទាំងអស់នេះឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនក្នុងការកម្លាយ ខ្លួនជាធនាគារពាណិជ្ជនាពេលអនាគត។

**២០១១** ហត្ថាកសិករបានបំពាក់ប្រព័ន្ធគ្រប់គ្រងធនាគារថ្មីដែលមានឈ្មោះថា Core Banking System បានយ៉ាងជោគជ័យដូចផែនការដែលបានកំណត់។ ប្រព័ន្ធគ្រប់គ្រងធនាគារថ្មីនេះអាចផ្តល់លទ្ធភាពឲ្យអតិថិជន និងសាធារណៈជនដកប្រាក់បានគ្រប់ទីកន្លែងតាមការិយាល័យ ហត្ថាកសិករ លីមីតធីត។ ស្របពេលជាមួយនេះដែរ ហត្ថាកសិករ លីមីតធីត ទទួលបានចំណាត់ថ្នាក់កំរិត “ A-” បន្ទាប់ពីវាយតំលៃលើចំណាត់ថ្នាក់អាជីវកម្ម ដែលបានធ្វើឡើងដោយស្ថាប័នផ្តល់ចំណាត់ថ្នាក់ហិរញ្ញវត្ថុមួយ។ ដែលជាសក្ខីភាពបង្ហាញយ៉ាងជាក់ច្បាស់អំពីភាពល្អឥតខ្ចោះ នៃប្រតិបត្តិការ និង ការអនុវត្តន៍ របស់ ហត្ថាកសិករ លីមីតធីត ។ ទាំងនេះសបញ្ជាក់ឲ្យឃើញពីស្ថិរភាពរបស់ ហត្ថាកសិករ បើទោះបីជាទទួលរងការប៉ះពាល់ពីព្រឹត្តិការណ៍ខាងក្នុងនិងខាងក្រៅយ៉ាងណាក្តី និង ការគ្រប់គ្រងហានិភ័យត្រូវបានពិនិត្យមើលយ៉ាងត្រឹមត្រូវ នឹងបានគ្រប់គ្រងកាត់បន្ថយហានិភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។

**២០១២** ហត្ថាកសិករ លីមីតធីត បានដាក់ឲ្យប្រើប្រាស់បានយ៉ាងជោគជ័យនូវប្រព័ន្ធគ្រប់គ្រងធនាគារថ្មីនៅគ្រប់បណ្តាញការិយាល័យប្រតិបត្តិការទាំងអស់។ ប្រព័ន្ធគ្រប់គ្រងធនាគារថ្មីនេះ បានបង្កើនប្រសិទ្ធភាព និង ផលិតភាពការងារអាជីវកម្មកាន់តែប្រសើរឡើងៗ។ បន្ថែមពីនេះ ហត្ថាកសិករ បានវិនិយោគលើគំរោងបង្កើតអោយមានសេវាអេធីអឹម និងប្រព័ន្ធធនាគារចល័តសំរាប់អតិថិជន។ ការវិនិយោគទៅលើបច្ចេកវិទ្យាទំនើបនេះ គឺដើម្បីអោយកាន់តែមានភាពសំបូរបែបនូវសេវាហិរញ្ញវត្ថុសំរាប់អតិថិជន និងដើម្បីបង្កើននូវប្រសិទ្ធភាពនៃការបម្រើសេវាអតិថិជន អោយកាន់តែរហ័សទាន់ចិត្ត និងមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការសាច់ប្រាក់ តាមរយៈម៉ាស៊ីនអេធីអឹម ដក-ដាក់ប្រាក់ និងសេវាធនាគារ ចល័តរបស់ ហត្ថាកសិករលីមីតធីត។ ជាមួយនឹងម៉ាស៊ីនអេធីអឹមដ៏ទំនើបដែលមិនធ្លាប់មាន និងប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងប្រព័ន្ធធនាគារចល័ត អតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានច្រើនយ៉ាងដូចជា ដក ប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ប្តូរប្រាក់ ព្រមទាំងទិញកាតទូរស័ព្ទតាមតំរូវការ។ ម៉ាស៊ីនអេធីអឹមដ៏ទំនើបនេះ បានដាក់ឲ្យអតិថិជន និងសាធារណៈជនប្រើប្រាស់បានជាផ្លូវការនៅចុងឆ្នាំ ២០១២ កន្លងទៅនេះ។

**២០១៣** ជាឆ្នាំប្រកបដោយភាពច្នៃប្រឌិតខ្ពស់ និងការបង្កើតផលិតផល និងសេវាកម្មហិរញ្ញវត្ថុថ្មីៗជាច្រើន ដែលបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជនដូចជាឥណទានបរិស្ថាន ឥណទាននិស្សិតខ្មែរ និងសេវាកម្មសាររលឹកពីប្រតិបត្តិការ។ ជាងនេះទៅទៀតដើម្បីបំពេញតម្រូវការអតិថិជនដែលប្រកបដោយវិជ្ជាជីវៈរហ័សទាន់ចិត្ត និងងាយស្រួលដល់អតិថិជន។ ហត្ថាកសិករ បានបំពាក់នូវប្រពន្ធមជ្ឈមណ្ឌផ្តល់ព័ត៌មានបានយ៉ាងជោគជ័យ។ ប្រពន្ធនេះអនុញ្ញាតអោយហត្ថាកសិករ បម្រើសេវាកម្មកាន់តែប្រសើរឡើងបន្ថែមទៀតជូនអតិថិជន ព្រមទាំងបង្កើតនូវគោលការណ៍ដើម្បីប្រមូលនូវការរអ៊ូរទាំ និងព័ត៌មានត្រឡប់ពីអតិថិជនដើម្បីធ្វើអោយប្រសើរឡើងនូវការអនុវត្តន៍ ។

**២០១៤** ជាឆ្នាំនៃសមិទ្ធិផលប្រកបដោយផ្លែផ្កា ទាំងប្រាក់បញ្ញើសន្សំ ឥណទាន និងផលិតផលផ្សេងៗទៀត។ ដោយយោងទៅលើនិរន្តរភាពផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ និងអភិបាលកិច្ចល្អ ហត្ថាកសិករបានបង្កើនដើមទុនរបស់ខ្លួនពី ៤,០៣៦,៨០០ ដុល្លារទៅដល់៥,២៧១,១៨៨ដុល្លារ ជាមួយនឹងធនាគារជាតិនៃកម្ពុជា។ ការបង្កើនដើមទុននេះអនុញ្ញាតអោយហត្ថាកសិករ លីមីតធីត មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួនទូទាំងប្រទេសកម្ពុជា។

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល



## លោក អេរិចផេធ័រឃើត

( Erik Peter Geurts )

ប្រធានក្រុមប្រឹក្សាភិបាល

ភាពតានតឹងខាងនយោបាយក្រោយការបោះឆ្នោតឆ្នាំ២០១៣ បានស្ងប់ស្ងាត់ខណៈពេលដែលរាជរដ្ឋាភិបាល និងគណបក្សសំលេងភាគតិចបានចាប់ផ្តើមការសន្ទនាដោយផ្តោតលើការដឹកនាំប្រទេសជាតិនាពេលខាងមុខ។ ជាការជំនួសមកវិញប្រទេសជាតិត្រូវដោះស្រាយចលាចលក្នុងសង្គមមួយចំនួន ជាពិសេសលើលក្ខខណ្ឌការងារនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ។ ទីបំផុត រាជរដ្ឋាភិបាលបានធ្វើអន្តរាគមន៍ដោយចេញអនុក្រិត្យតម្លើងប្រាក់ឈ្នួលសមស្របមួយដែលមិនមានផលប៉ះពាល់លើផលប្រយោជន៍ផលិតកម្មរបស់កម្ពុជា។ ភាពចលាចលនេះមិនបានផ្តល់ផលប៉ះពាល់ដោយផ្ទាល់ទៅលើឧស្សាហកម្មមីក្រូហិរញ្ញវត្ថុនោះទេ តែវាបានគូសបញ្ជាក់អំពីសារៈសំខាន់នៃគោលនយោបាយទំនួលខុសត្រូវធនធានមនុស្សក្នុងសង្គមដែលជាទូទៅគោលនយោបាយទាំងនេះត្រូវបានអនុវត្តនៅក្នុងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុកម្ពុជា។

ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុមានការផ្លាស់ប្តូរគួរអោយកត់សម្គាល់ បន្ទាប់ពីមានការពង្រីកខ្លួនយ៉ាងគំហុកពីសំណាក់ក្រុមហ៊ុនចំនួន ០២ដែលទើបតែចូលប្រឡូកក្នុងទីផ្សារ។ ទោះបីជាក្រុមហ៊ុនទាំងពីរនេះមិនបានផ្តល់របាយការណ៍ទៅកាន់សមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ( CMA ) ក៏ដោយ ក៏ក្រុមហ៊ុនទាំងនេះកំពុងលេចធ្លោយ៉ាងខ្លាំងនៅក្នុងទីផ្សារដែរ។ សកម្មភាពរបស់ក្រុមហ៊ុនថ្មីនេះបានជំរុញអោយគ្រឹះស្ថានដទៃទៀតដាក់លក់ផលិតផលដែលអាចបត់បែនបានកាន់តែខ្លាំងជាងមុន។ ជាលទ្ធផល លក្ខណៈនិងទំហំឥណទាននៅក្នុងឧស្សាហកម្មនេះមានការកើនឡើង។ យើងបានមើលឃើញពីការពង្រីកហិរញ្ញវត្ថុសំរាប់ការប្រើប្រាស់ទៅកាន់ប្រជាជនដែលមានប្រាក់ចំណូលទាបផងដែរ។ វានៅមានកំរិតនៅឡើយសំរាប់រាជធានីភ្នំពេញដែលហិរញ្ញវត្ថុប្រភេទនេះត្រូវបានរឹតបួតដោយហាងទំនិញដែលកាន់កាប់ដោយក្រុមហ៊ុនអន្តរជាតិជាច្រើន។

ហត្ថាកសិករ មិនទទួលរងផលប៉ះពាល់នៅឡើយទេចំពោះការផ្លាស់ប្តូរថ្មីនេះ ពីព្រោះថាហត្ថាកសិករកំពុងផ្តល់ប្រាក់កម្ចីយ៉ាងសន្ធឹកសន្ធាប់នៅតាមតំបន់ជនបទនានាក្នុងប្រទេស។ នៅឆ្នាំ២០១៤ ហត្ថាកសិករបានខិតខំយកចិត្តទុកដាក់ផ្តោតលើការបង្កើនចំណែកទីផ្សារនិងការថែរក្សាអតិថិជនរបស់ខ្លួនយ៉ាងប្រុងប្រយ័ត្ន។ ផលប័ត្របានកើនឡើង ៧២%ធៀបនឹង ៤៥% សំរាប់វិស័យមីក្រូហិរញ្ញវត្ថុដែលបានផ្សារភ្ជាប់ជាមួយ CMA។ ដើម្បីជម្រុញកំណើនអោយបានខ្លាំងជាងមុន ហត្ថាកសិករបានបង្កើនដើមទុនពីភាគទុនិក

ចំនួន១០លានដុល្លារអាមេរិកបន្ថែមទៀត។ ដើមទុននេះនឹងត្រូវសងក្នុងអំឡុងឆមាសទី១ ក្នុងឆ្នាំ២០១៥អាស្រ័យលើការអនុម័ត។ គណៈគ្រប់គ្រងកំពុងចរចាបន្ថែមលើអនុបំណុលដើម្បីធានាលើកំណើន និងបង្កើនចំណែកទីផ្សារផងដែរ។

ហត្ថាកសិករដឹងច្បាស់លាស់ថានៅក្នុងទីផ្សារប្រកួតប្រជែងដែលកំពុងកើនឡើងខ្លាំង ការថែរក្សាអតិថិជននិងបុគ្គលិកមានសារៈសំខាន់បំផុត។ ដើម្បីអាចឆ្លើយតបនឹងការរំពឹងទុករបស់ភាគទុនិក ក្រុមហ៊ុននឹងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍផលិតផល និងបណ្តាញមធ្យោបាយប្រតិបត្តិការថ្មីៗ ដើម្បីបំពេញតម្រូវការអតិថិជន និងធ្វើអោយដំណើរការកាន់តែមានប្រសិទ្ធភាពជាងមុនបន្ថែមទៀត។ ជាមួយគ្នានេះដែរ ហត្ថាកសិករបាននឹងកំពុងស្វែងរកភាពជាដៃគូដើម្បីអោយការបម្រើសេវាកម្មអតិថិជនកាន់តែប្រសើរជាងមុន។ តួយ៉ាង ហត្ថាកសិករបានចាប់ដៃគូជាមួយធនាគារ ANZ Royal ដោយមើលឃើញថាហត្ថាកសិករជាដៃគូដ៏ល្អបំផុតមួយក្នុងការជួយដល់អតិថិជនដែលមានប្រាក់ចំណូលទាបនៅតាមតំបន់ជនបទ។ ប្រតិបត្តិការនាពេលខាងមុខ បច្ចេកវិទ្យាជាច្រើននឹងត្រូវបានជំរុញបន្ថែមទៀត ហើយការផ្តល់ទុននឹងត្រូវបានប្រើប្រាស់លើសេវាប្រាក់បញ្ញើសន្សំ។

យើងអាចសន្និដ្ឋានបានថា ឆ្នាំ២០១៤ជាឆ្នាំដែលទទួលបានជោគជ័យយ៉ាងខ្លាំង។ យើងមានការរីកចំរើនជាងការប្រកួតប្រជែងរក្សាគុណភាពផលប័ត្របានល្អ និងឈានដល់ទំហំសេដ្ឋកិច្ចដែលបានអនុញ្ញាតសម្រាប់ ROE 26% ទល់នឹង១៩% តិចជាងឆ្នាំមុន។ យើងកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅកាន់ការក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការប្រកួតប្រជែងខ្លាំងជាងគេមួយ ក្នុងការជ្រោមជ្រែងសហគ្រិនខ្នាតតូចបំផុត តូច និងមធ្យមនៅគ្រប់តំបន់ក្នុងប្រទេសកម្ពុជា។

ជំនួសមុខអោយក្រុមប្រឹក្សាភិបាលទាំងអស់ ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បុគ្គលិក និងគណៈគ្រប់គ្រង ព្រមទាំងអតិថិជនទាំងអស់ សម្រាប់ការគាំទ្រដ៏ស្មោះសរមកលើក្រុមហ៊ុន។ ទំនុកចិត្តដែលទទួលបានពីអតិថិជនប្រាក់កម្ចី អតិថិជនប្រាក់សន្សំ អតិថិជនប្រាក់បញ្ញើ និងភាគហ៊ុននិកទាំងអស់នេះ បានលើកទឹកចិត្តពួកយើងអោយរក្សាបាននូវមហិច្ឆតារបស់ពួកយើងជានិច្ច ។

ដោយក្តីគោរពចំពោះក្រុមប្រឹក្សាភិបាល ខ្ញុំសូមប្រកាសពីការផ្លាស់ប្តូរចំនួនពីរ ។ ទីមួយ លោកប្រធានអគ្គនាយក និងជាសហស្ថាបនិកនៃហត្ថាកសិករបានសម្រេចចិត្តចាកចេញពីក្រុមប្រឹក្សាភិបាលដើម្បីផ្តោតលើតួនាទីប្រតិបត្តិរបស់លោក។ហេតុការណ៍នេះកើតឡើងបន្ទាប់ពីមានសំណូមពររបស់លោក **ហួត អៀងតុង** ដែលចង់ចូលរួមអោយមានអភិបាលកិច្ចល្អ និងការញែកដាច់ពីគ្នាយ៉ាងច្បាស់លាស់រវាងតួនាទីរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង។ អង្គការក្រៅរដ្ឋាភិបាលដែលជាស្ថាបនិកក្រុមហ៊ុនបានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការតែងតាំងអ្នកជំនួស។ យើងរីករាយយ៉ាងខ្លាំងក្នុងការទទួលបានលោក **ប៉ាក់ សេរីវឌ្ឍនា** មកធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលជំនួស លោក **ហួត អៀងតុង** ។ ជាមួយនឹងបទពិសោធន៍យ៉ាងច្រើនក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា លោក **ប៉ាក់ សេរីវឌ្ឍនា** នឹងបន្ថែមគុណតម្លៃបន្ថែមទៀតទៅលើក្រុមប្រឹក្សាភិបាលរបស់យើង។ ទីពីរ លោក Christensen Røed បានសម្រេចចិត្តចាកចេញពីក្រុមប្រឹក្សាភិបាលក្រោមហេតុផលផ្ទាល់ខ្លួន។ លោក Christensen បានចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចែករំលែកបទពិសោធន៍ដ៏យូរ និងជាសកលក្នុងការគ្រប់គ្រងធនាគារទៅកាន់ក្រុមប្រឹក្សាភិបាលព្រមទាំងគណៈគ្រប់គ្រងទាំងអស់របស់ហត្ថាកសិករ។ ក្នុងនាមជាប្រធានគណៈកម្មការឥណទាននៃក្រុមប្រឹក្សាភិបាល លោកបានចុះពិនិត្យសាខា និងអតិថិជនដើម្បីគាំទ្រដល់ប្រតិបត្តិការផ្តល់ប្រាក់កម្ចីរបស់ក្រុមហ៊ុនកាន់តែប្រសើរឡើង។ យើងនឹងបាត់បង់នូវការរួមចំណែករបស់គាត់។ នៅពេលជាមួយគ្នានេះដែរ យើងមានទំនុកចិត្តថា Norfund ដែលជាម្ចាស់ភាគហ៊ុនរបស់យើងនឹងស្វែងរកនូវសមាជិកក្រុមប្រឹក្សាភិបាលផ្សេងមកជំនួស លោក Christensen ។



Erik Peter Geurts
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់ប្រធានអគ្គនាយក



**ឧកញ៉ា ហួត អៀងតុង**
ប្រធានអគ្គនាយក

*“ ហត្ថាកសិករ ទទួលបានលទ្ធផលជាទីពេញចិត្តនៅក្នុងឆ្នាំ២០១៤ ជាមួយនឹងកំណើនសម្ភាធ ៧២% ធៀបនឹង ៤៥ % សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានផ្សារភ្ជាប់ជាមួយ CMA និងការកើនឡើងគួរអោយកត់សម្គាល់នូវប្រាក់ចំណេញ បើទោះជាមានចលាចលក្នុងសង្គមមួយចំនួនក្នុងវិស័យកាត់ដេរ ។”*

ការសម្រេចចិត្តជម្រុញការវិនិយោគប្រព័ន្ធបច្ចេកវិទ្យា និងការអភិវឌ្ឍផលិតផល ព្រមទាំងកំណើននៃសេវាធនាគារចល័តអនុញ្ញាតអោយយើងអាចផ្តល់សេវាកម្មដល់អតិថិជនបាន។

## បរិយាកាសប្រកួតប្រជែងនៃឧស្សាហកម្ម

ការប្រកួតប្រជែងរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗចំនួន៤នៅក្នុងប្រទេសកម្ពុជាមានការកើនឡើង ដែលជាដំណឹងល្អសម្រាប់អតិថិជននិងសាធារណជន។ជាងនេះទៅទៀតសម្ពាធនៃការប្រកួតប្រជែងបានកើតឡើងពីការពង្រីកខ្លួនយ៉ាងគំហុកពីសំណាក់ធនាគារចំនួនពីរដែលទើបចូលប្រឡូកក្នុងទីផ្សារថ្មីៗនេះ។ ថ្វីបើមានបញ្ហាបែបនេះក្តី យើងនៅតែមានកំណើនផលប័ត្ររបស់យើងច្រើនជាងការកើនឡើងនៃចំនួនឧស្សាហកម្ម និងការបង្កើនភាគហ៊ុនក្នុងការដាក់ប្រាក់បញ្ញើពី១៨% ទៅ២០% ។ នៅចុងឆ្នាំ២០១៤ ហត្ថាកសិករស្ថិតក្នុងចំណាត់ថ្នាក់លេខ២លើសម្ពាធប្រាក់បញ្ញើសន្សំក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗទាំង៤ (លេខ៤នៅឆ្នាំ២០១៣)។ ដើម្បីគាំទ្រដល់ការរីកចំរើនដ៏ឆាប់រហ័ស និងការវិនិយោគបច្ចេកវិទ្យាថ្មីៗអោយសមស្រប ជាមួយនឹងការរីកចម្រើននេះ ភាគទុនិកបានសម្រេចបង្កើនដើមទុនចំនួន ៦លានដុល្លារអាមេរិកបន្ថែមទៀតនៅដើមឆ្នាំ២០១៤ ដែលធ្វើអោយយើងអាចទាញយកផលប្រយោជន៍បានពីកាលានុវត្តភាពដែលជាអំណោយផលពីបរិយាកាសសេដ្ឋកិច្ចនេះ។

## សកម្មភាពប្រតិបត្តិការនៅឆ្នាំ២០១៤

- ហត្ថាកសិករ រក្សាបាននូវការរីកចម្រើនយ៉ាងប្រសើរដោយសម្ពាធប្រាក់បញ្ញើកើនទ្វេដងពី ៨៣.៣លានដុល្លារ ទៅ ១៧៣.៦លានដុល្លារ ថ្វីបើមានផលវិបាកមួយចំនួនដែលកើតចេញពីចលាចលនៅក្នុងវិស័យកាត់ដេរ ។
- ហត្ថាកសិករមានចំណូលហិរញ្ញវត្ថុរបស់ខ្លួនសរុបកើនឡើង៥០% ពី៣០លានដុល្លារ ទៅ៤៥លានដុល្លារ។ ក្នុងនោះសម្ពាធឥណទានដុលកើនឡើង៧២% ពី១៤៥.៦លានដុល្លារ ទៅ២៥០.១លានដុល្លារ។ ស្ទើរតែគ្រប់សាខាទាំងអស់របស់ ហត្ថាកសិករទទួលបានលទ្ធផលល្អប្រកបដោយគុណភាពខ្ពស់។

- ចំណូលពីការប្រាក់សុទ្ធបានកើនឡើង៤០% ពី២០.៤លានដុល្លារ ទៅ២៨.៦ លានដុល្លារ ដែលការចំណាយលើប្រតិបត្តិការកើនឡើង៣០.៤៦% ពី១៥.១លានដុល្លារ ទៅ១៩.៧លានដុល្លារ។ ការកើនឡើងនូវការចំណាយគឺដោយសារយើងមានតម្រូវការបុគ្គលិកដែលមានវិជ្ជាជីវៈ ការបណ្តុះបណ្តាល ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងការអនុវត្តលើការលើកទឹកចិត្តបុគ្គលិក។ យើងជឿជាក់ថា ការចំណាយទាំងនេះនឹងផ្តល់ផលមកវិញតាមរយៈការបង្កើនផលិតភាព និងប្រាក់ចំណេញបន្ថែម។
- សម្ពាធឥណទានដែលមានហានិភ័យមានការថយចុះទ្វេដងពី០.០៦% មក០.០៣% ដោយសារបំណុលមានហានិភ័យមានកំរិតកាន់តែទាប។
- ប្រតិបត្តិការហិរញ្ញវត្ថុរបស់យើងទទួលបានលើសពីកំរិតដែលបានកំណត់ដែលទទួលបានដើមទុនចំនួន២៥.៩៧% លើសពីគម្រោងថវិកាដែលមានត្រឹមតែ២០.៥២% ។
- ភ្នាក់ងារផ្តល់ចំណាត់ថ្នាក់ Planet Rating Agency ( Planet Rating Agency ) ដែលមានមូលដ្ឋាននៅប្រទេសបារាំងបានធ្វើការវាយតម្លៃហត្ថាកសិករលើសកម្មភាពក្នុងស្ថាប័ន និងសង្គមដោយបានបញ្ជាក់ថា ហត្ថាកសិករ កំពុងឈរក្នុងទីតាំងមួយដែលមានស្ថេរភាពក្នុងរយៈពេលខ្លី និងមធ្យម។ យើងក៏បានសម្រេចផងដែរនូវការដាក់បញ្ចូលប្រព័ន្ធព័ត៌មានបរិស្ថាននិងសង្គម ( E&S ) ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានMIS។

## ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ហត្ថាកសិករ បានបំពាក់ប្រព័ន្ធបច្ចេកវិទ្យាអនឡាញដ៏ទំនើបដែលបង្ហាញពីសមត្ថភាពគ្រាប់គ្រាន់ក្នុងការឆ្លើយតបនឹងការរីកចម្រើនរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាក់ស្តែងការិយាល័យសាខា និងសាខារងទាំងអស់បានបំពាក់ប្រព័ន្ធអនឡាញនេះរួចជាស្រេចដែលអាចបម្រើសេវាកម្មដល់អតិថិជនបានយ៉ាងរហ័ស ព្រមទាំងងាយស្រួល និងមានសុវត្ថិភាពខ្ពស់។

## បណ្តាញការិយាល័យ និងការអភិវឌ្ឍន៍ផលិតផល

បណ្តាញការិយាល័យប្រតិបត្តិការរបស់ហត្ថាកសិករបានកើនឡើងពី១៣៦ការិយាល័យក្នុងឆ្នាំ២០១៣ ដល់១៤២ការិយាល័យក្នុងឆ្នាំ២០១៤ ដែលធ្វើអោយយើងអាចផ្តល់សេវាកម្មហិរញ្ញវត្ថុទៅកាន់តំបន់ថ្មីៗ និងពង្រីកដែនប្រតិបត្តិការរបស់យើងអោយកាន់តែទូលាយថែមទៀត។ លើសពីនេះ យើងបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន៣៧បន្ថែមទៀត ដែលធ្វើអោយចំនួនម៉ាស៊ីនអេធីអឹមសរុបទាំងអស់កើនដល់៧២នៅចុងឆ្នាំ២០១៤ គ្របដណ្តប់ទូទាំង២៥ខេត្ត-រាជធានី ដែលអាចបម្រើអតិថិជន ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ និង៣៦៥ថ្ងៃក្នុងមួយឆ្នាំ ដោយរួមបញ្ចូលទាំងថ្ងៃឈប់សម្រាក បុណ្យជាតិ និងអន្តរជាតិផងដែរ។ ជាមួយម៉ាស៊ីនអេធីអឹម ហត្ថាកសិករ អតិថិជនអាចធ្វើប្រតិបត្តិការបានគ្រប់ពេលវេលាទាំងអស់ ដូចជាពិនិត្យសមតុល្យក្នុងគណនី ពិនិត្យរបាយការណ៍សង្ខេប ផ្ទេរប្រាក់ពីអ្នកមានគណនីទៅអ្នកមានគណនី ផ្ទេរប្រាក់ពីអ្នកមានគណនីទៅអ្នកគ្មានគណនីទូទាត់សងឥណទាន សេវាទូទាត់ផ្សេងៗ និងទិញកាតទូរស័ព្ទជាដើម។

ហត្ថាកសិករ បានដាក់អោយប្រើប្រាស់សាកល្បងផលិតផលឥណទានថ្មី គឺឥណទានកែលម្អ និងសាងសង់គេហដ្ឋាន ហើយយើងទទួលបានលទ្ធផលជាទីគាប់ចិត្ត។

ចំពោះផលិតផលកម្រៃសេវា អគ្គនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្មបានតម្រង់ទិសទៅលើសេវាទិញកាតទូរស័ព្ទ សេវាទូទាត់វិក្កយបត្រ សេវាធនាគារចល័ត សេវាទូទាត់ផ្សេងៗសហការជាមួយធនាគារ ANZ Royal ( ដំណាក់កាលសាកល្បង ) និងចាប់ដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចប្រេវ័រ( កម្ពុជា ) Prevoir Kampuchea Micro-life Insurance Plc ដើម្បីផ្តល់សេវាធានារ៉ាប់រងខ្នាតតូចទៅលើសុខភាព និងអាយុជីវិតទៅដល់អតិថិជនប្រាក់កម្ចី និងប្រាក់សន្សំរបស់ហត្ថាកសិករ( ដំណាក់កាលសាកល្បង )។លក្ខណៈផលិតផលរបស់សេវាធនាគារចល័ត ត្រូវបានសម្រិតសម្រាំងឡើងដើម្បីអោយសមស្របជាមួយនឹងទីផ្សារ។

## សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៥

- បន្តធ្វើការអភិវឌ្ឍផលិតផល និងបង្កើនការលក់ផលិតផលហិរញ្ញវត្ថុអោយបានច្រើន ព្រមទាំងធ្វើភតិសន្យាផលិតផល និង ឥណទានប្រើប្រាស់ ។
- ថែទាំគុណភាពទ្រព្យសកម្ម និងអភិវឌ្ឍផលិតផលកម្រៃសេវាអោយកាន់តែប្រសើរឡើង។
- ធ្វើអោយសម្រេចការតាំងចិត្តរបស់យើងក្នុងការផ្តល់សេវាកម្មប្រកបដោយគុណភាព និងភាពងាយស្រួលដល់អតិថិជន ២៤ម៉ោងក្នុងមួយថ្ងៃ និង៣៦៥ថ្ងៃក្នុងមួយឆ្នាំ។
- ណែនាំផលិតផលធនាគារចល័តដល់អតិថិជន និងសាធារណជន។

## សេចក្តីថ្លែងអំណរគុណ

អ្វីៗទាំងអស់ដែលយើងទទួលបានកាលពីឆ្នាំមុន អ្វីៗដែលយើងទទួលបាននៅថ្ងៃនេះ និងអ្វីៗទាំងអស់ដែលយើងអាចមានការលេចធ្លោរហូតមកដល់ពេលនេះ គឺជាការចូលរួមយ៉ាងសំខាន់ពីម្ចាស់ភាគហ៊ុនរបស់យើង។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ការលះបង់របស់បុគ្គលិកយើងទាំងអស់ អតិថិជនដែលស្មោះស្ម័គ្រជាមួយយើង ដៃគូអាជីវកម្មដែលជឿជាក់យើង និងការចូលរួមព្រមទាំងការគាំទ្រពីធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលជាមគ្គុទេសក៍ល្អរបស់យើងកន្លងមក។ ខ្ញុំសូមថ្លែងអំណរគុណចំពោះប្រធានក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគទុននិកសំរាប់អនុសាសន៍ផ្សេងៗ និងគាំទ្រអោយខ្ញុំបន្តដឹកនាំហត្ថាកសិករតទៅទៀត។ ក្នុងនោះផងដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់គ្រប់គ្រងគ្រប់លំដាប់ និងសហសេវិកទាំងអស់ដែលបានគាំទ្រ និងខិតខំប្រឹងប្រែងដើម្បីធ្វើអោយហត្ថាកសិករកាន់តែរីកចម្រើននិងឆ្ពោះទៅមុខទៀត។



ឧកញ៉ា ហួត អៀងតុង
ប្រធានអគ្គនាយក

# រចនាសម្ព័ន្ធមូលធនសាជីវកម្ម




ការរីកចម្រើនដ៏សំខាន់នៃសំពាធឥណទាន និងបញ្ញើសន្សំ រួមទាំងចំនួននៃអ្នកខ្ចី និងអ្នកដាក់ប្រាក់បញ្ញើបានកើនឡើងជាបន្តបន្ទាប់នៅហត្ថាកសិករ ។ ហត្ថាកសិករ រក្សាបាននូវរចនាសម្ព័ន្ធមូលធនដែលមានម្ចាស់ភាគហ៊ុនដ៏ខ្លាំងចំនួន៨ពីប្រទេសខុសៗគ្នា។

| **ភាគទុននិក** | **ចំនួនភាគហ៊ុន (%)** |
|---|---|
| អូយកូក្រេឌីត | ១៩.៨៧ |
| អេអិនអឹមអេហ្វ-ត្រាយផលចាំ | ១៧.៤៩ |
| ន័ហ្វាន់ | ១៩.៧៣ |
| អង្គការហត្ថាកសិករ | ១៣.២០ |
| វេស្ទនស៊ីប៊ីលីធី | ១០.៦០ |
| វេស្ទនស៊ីប៊ីលីធី ផាតធីស៊ីផេសិន អេជី | ៩.១៥ |
| សមាគមបុគ្គលិកហត្ថាកសិករ | ៨.៩០ |
| បណ្ឌិត ឌី ដារ៉ុធ | ១.០៦ |
| **សរុប** | **១០០** |

ខាងក្រោមនេះ ជាព័ត៌មានសង្ខេបរបស់ភាគទុនិកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត គិតត្រឹមខែធ្នូ ឆ្នាំ២០១៤ ៖

**អូយកូក្រេឌីត (Oikocredit)** អូយកូក្រេឌីត គឺជាស្ថាប័នហិរញ្ញវត្ថុធំមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុនានា នៅលើពិភពលោកដែលផ្តល់មូលនិធិសំរាប់វិស័យមីក្រូហិរញ្ញវត្ថុ។ ស្ថាប័ននេះផ្តល់នូវឥណទានមូលធនដល់សហគ្រាសខ្នាតតូចផ្សេងៗតាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ និងដល់ក្រុមហ៊ុនពាណិជ្ជកម្ម អង្គភាពអាជីវកម្មខ្នាតមធ្យមនិងសហ គ្រាសខ្នាតតូចនិងមធ្យមដោយផ្ទាល់។ អូយកូក្រេឌីត មានស្នាក់ការនៅ ទីក្រុង Ammersfoort នៃប្រទេសហូឡង់ ដែលមានការិយាល័យតំណាងនៅតាមបណ្តាប្រទេសជាង៣០ ជុំវិញពិភពលោក។ ការិយាល័យទាំងនេះ ជាអ្នកត្រួតពិនិត្យមើលលើដៃគូគំរោងផ្សេងៗនៅក្នុងប្រទេសជាង ៦៥។ ប្រភពទុនសំរាប់ផ្តល់ហិរញ្ញប្បទានដល់គំរោងអភិវឌ្ឍន៍នានា បានមកពីការវិនិយោគនានានៃភាគទុនិករបស់អូយកូក្រេឌីត ដែលរួមមានបុគ្គលឯកជនចំនួនជាង ៤០,០០០នាក់ អង្គការដែលមានទំនាក់ទំនងវិហារសាសនាជាង ៦០០០ស្ថាប័ន និងស្ថាប័នដទៃទៀតជាច្រើននៅជុំវិញពិភពលោក។ សំរាប់ព័ត៌មានបន្ថែម សូមទស្សនាគេហទំព័រ www. oikocredit.org។

**អេអិនអឹមអែហ្វ-ត្រាយផលចាំ (ANMF Triple Jump)** អេអិនអឹមអែហ្វត្រាយផលចាំ ( ANMF Triple Jump ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ដោយធនាគារ ASN Bank N.V និងអង្គការអភិវឌ្ឍន៍ Oxfam-Novib ដើម្បីផ្តល់ហិរញ្ញវត្ថុសំរាប់វិស័យមីក្រូហិរញ្ញវត្ថុ។ ដោយមានគោលដៅលើកទឹកចិត្តអោយមានការចូលរួមពីសង្គមគ្រប់លំដាប់ថ្នាក់ក្នុងទីផ្សារសេដ្ឋកិច្ច តាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានាអោយបានទូលំទូលាយ អេអិនអឹមអែហ្វ បានអនុញ្ញាតអោយបុគ្គលឯកជនធ្វើការវិនិយោគក្នុងអន្តរការីហិរញ្ញវត្ថុតាមរយៈការបញ្ចេញភាគហ៊ុនយ៉ាងច្រើនដែលអាចជួញដូរបានប្រចាំថ្ងៃ។ អេអិនអឹមអែហ្វ វិនិយោគដើម្បីពង្រីក និងបង្កភាពចាស់ទុំដល់អន្តរការីហិរញ្ញវត្ថុ ព្រមទាំងធ្វើប្រតិបត្តិការនៅតាមបណ្តាប្រទេសនានាក្នុងទ្វីបអាហ្វ្រិក អាស៊ី អឺរ៉ុបខាងកើត និងអាមេរិកឡាទីន។ អេអិនអឹមអែហ្វ មានលទ្ធភាពផ្តល់មូលធនរយៈពេលវែង និងផ្តល់បំណុលអាទិភាព អនុបំណុលនៅក្នុងការវិនិយោគបន្តបន្ទាប់ ដែលមូលនិធិទាំងនោះត្រូវបានលក់អោយអតិថិជនតាមរយៈធនាគារ ASN Bank។ ទ្រព្យសកម្មរបស់ស្ថាប័ននេះត្រូវបានគ្រប់គ្រង និងចាត់ចែងដោយ Triple Jump B.V ដែលជាអ្នកឯកទេសលើការគ្រប់គ្រងវិនិយោគ និងប្រឹក្សាយោបល់ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ នៅចុងឆ្នាំ២០១៤ ទ្រព្យសកម្មសរុបរបស់ អេអិនអឹមអែហ្វ មានចំនួន២៤០លានអឺរ៉ូ។ ទឹកប្រាក់នេះត្រូវបានគេប្រើប្រាស់ចំនួន ២០២លានអឺរ៉ូ សំរាប់ជាបំណុលអាទិភាព អនុបំណុល និងសំរាប់ទ្រព្យម្ចាស់ក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួន ៩៩ នៅក្នុងទ្វីបទាំង ០៥។ ព័ត៌មានលំអិតលើការវិនិយោគរបស់ អេអិនអឹមអែហ្វ និងមូលនិធិដទៃទៀតដែលគ្រប់គ្រង និងចាត់ចែងដោយត្រាយផលចាំសូមទស្សនា គេហទំព័រ www.triplejump.eu ។

**ន័រហ្វាន់ (Norfund)** ន័រហ្វាន់ គឺជាស្ថាប័នដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលន័រវេ និងបានចាប់ផ្តើមប្រតិបត្តិការនៅឆ្នាំ១៩៩៨។ ក្រុមហ៊ុននេះ គឺជាទម្រង់ក្រុមហ៊ុនដែលមានការទទួលខុសត្រូវមានកំណត់ ហើយសមាសភាពថ្នាក់ដឹកនាំដែលរួមមានក្រុមប្រឹក្សាភិបាល និងប្រធានក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយរដ្ឋាភិបាលន័រវេ។ គោលបំណងរបស់ន័រហ្វាន់ គឺការវិនិយោគមូលធននៅតាមក្រុមហ៊ុនឯកជននានា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលធ្វើឱ្យក្រុមហ៊ុនទាំងនោះមានការរីកចំរើន តាមរយៈមធ្យោបាយដែលមាននិរន្តរភាព។ នៅចុងឆ្នាំ ២០១៤នេះ ន័រហ្វាន់មានដើមទុនសរុបចំនួន ១,៨០០ លានដុល្លារអាមេរិក ហើយរំពឹងថាដើមទុននេះនឹងកើនឡើងបន្តទៀតនៅក្នុងរយៈពេលខាងមុខ។ ន័រហ្វាន់មានគម្រោងក្លាយទៅជាមូលនិធិវិនិយោគឈានមុខគេនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយធ្វើយ៉ាងណាឱ្យមានជំហរហិរញ្ញវត្ថុរឹងមាំ រួមផ្សំជាមួយនឹងជំនាញ គ្រប់គ្រងការវិនិយោគប្រកបដោយគុណភាពខ្ពស់ និងបទពិសោធន៍ទូលំទូលាយ។ ន័រហ្វាន់ ផ្តោតការវិនិយោគនៅក្នុងស្ថាប័នហិរញ្ញវត្ថុមូលនិធិវិនិយោគសហគ្រាសខ្នាតតូច មធ្យមវិស័យកសិកម្ម និងវិស័យថាមពលកកើតឡើងវិញ។ ព័ត៌មានផ្សេងៗសូមទស្សនាគេហទំព័ររបស់ន័រហ្វាន់ www.norfund.no។

## HATTHA KAKSEKAR NGO (HK NGO)

**អង្គការហត្ថាកសិករ (HKL NGO)** អង្គការហត្ថាកសិករ មានដើមកំនើតមកពីគំរោងសន្តិសុខស្បៀងនៅឆ្នាំ១៩៩៦។ នៅក្នុងខែតុលា ឆ្នាំ២០០១ អង្គការនេះបានធ្វើការកែទំរង់រចនាសម្ព័ន្ធរបស់ខ្លួនដើម្បីក្លាយទៅជាភាគទុនិករបស់ ហត្ថាកសិករ លីមីតធីត។ ដូច្នេះទ្រព្យសកម្ម និងមូលធនរបស់អង្គការនេះត្រូវបានផ្ទេរចូលទៅជាទ្រព្យសកម្មរបស់ហត្ថាកសិករ លីមីតធីត។ ដំបូងឡើយ ភាគហ៊ុនរបស់អង្គការហត្ថាកសិករមានត្រឹមតែ ៣៥,០១០ដុល្លារ ដែលស្មើនឹង៤៥%នៃភាគហ៊ុនរបស់ហត្ថាកសិករ លីមីតធីត ទាំងអស់។ ដោយសារមានការបន្ថែមទំហំទឹកប្រាក់វិនិយោគពីដៃគូខាងក្រៅអង្គការហត្ថាកសិករបានបង្កើននូវដើមទុនរបស់ខ្លួនរហូតដល់ ១២៨,៥៥០ដុល្លារ។ គិតត្រឹមចុងឆ្នាំ២០១៤ ភាគហ៊ុនរបស់ អង្គការហត្ថាកសិករមានចំនួន ៦៩៥,៨៣០ដុល្លារ ដែលស្មើនឹង១៣.២០% នៃភាគហ៊ុនសរុបរបស់ ហត្ថាកសិករ លីមីតធីត។

**រេស្ពនស៊ីប៊ីលីធី ផាតធីស៊ីផេសិន អេជី responsAbility Participation AG (rAP)** រេស្ពនស៊ីប៊ីលីធី ផាតធីស៊ីផេសិន អេជី ជាក្រុមហ៊ុនដែលកំណត់ដោយភាគហ៊ុនជាច្រើនហើយមានទីតាំងការិយាល័យរបស់ខ្លួននៅទីក្រុង Zurich ប្រទេសស្វីស។ ក្រុមហ៊ុនមានគោលដៅចូលរួមរយៈពេលវែងជាមួយក្រុមហ៊ុននានាក្នុងការធ្វើអោយរីកចម្រើននិងបំលាស់ប្តូរសេដ្ឋកិច្ចក្រោមការផ្តោតជាពិសេសលើគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយណា ដែលផ្តល់សេវាហិរញ្ញវត្ថុទៅដល់សហគ្រាសខ្នាតតូចបំផុត តូច និងមធ្យម ឬអតិថិជនដែលមានប្រាក់ចំណូលទាប។ រេស្ពនស៊ីប៊ីលីធី ផាតធីស៊ីផេសិន អេជី គ្រប់គ្រង និងចាត់ចែងដោយរេស្ពនស៊ីប៊ីលីធី អ៊ីនវែសមិន អេជី ដែលជាក្រុមហ៊ុនឈានមុខគេមួយក្នុងការគ្រប់គ្រងទ្រព្យសកម្មដោយឯករាជ្យ និងមានបទពិសោធន៍ជាងមួយទសវត្សរ៍ក្នុងការអភិវឌ្ឍការវិនិយោគហើយមានទ្រព្យសកម្មសរុបចំនួន២.៤ពាន់លានដុល្លារអាមេរិកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។

**រេស្ពនស៊ីប៊ីលីធី responsAbility** រេស្ពនស៊ីប៊ីលីធី គឺជាក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មដោយឯករាជ្យឈានមុខគេមួយនៅលើពិភពលោកក្នុងការអភិវឌ្ឍការវិនិយោគ និងផ្តល់ដំណោះស្រាយការគ្រប់គ្រងវិនិយោគប្រកបដោយវិជ្ជាជីវៈទៅកាន់វិស័យឯកជន និងស្ថាប័នរដ្ឋ។ រេស្ពនស៊ីប៊ីលីធី ផ្តោតការវិនិយោគផ្នែកឥណទាន និងទ្រព្យជាម្ចាស់ទៅដល់ស្ថាប័នដើម្បីជម្រុញអោយមានការរីកចម្រើនសេដ្ឋកិច្ច និងប្រទេសជាតិ។ រេស្ពនស៊ីប៊ីលីធី មានទ្រព្យសម្បត្តិសកម្មសរុប ២.៤ ពាន់លានដុល្លារអាមេរិក ដែលបាននិងកំពុងវិនិយោគ ជាមួយក្រុមហ៊ុនជាង ៥៣០ នៅក្នុង ៩០ ប្រទេសទូទាំងពិភពលោក។ បង្កើតឡើងក្នុងឆ្នាំ ២០០៣ រេស្ពនស៊ីប៊ីលីធី មានការិយាល័យកណ្តាលនៅក្នុងទីក្រុង Zurich និងមានទីស្នាក់ការនៅទីក្រុង Paris, Lima, Mumbai និង Nairobi។ ស្ថាប័ននេះ មានភាគទុននិកជាស្ថាប័នល្បីៗនៅក្នុងទីផ្សារហិរញ្ញវត្ថុនៃប្រទេសស្វីស និងបុគ្គលិករបស់ស្ថាប័ន។ បន្ថែមពីលើនេះ រេស្ពនស៊ីប៊ីលីធី បានចុះបញ្ជីជាមួយនឹងអាជ្ញាធរគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុនៃប្រទេសស្វីស FINMA ផងដែរ ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.responsAbility.com។

**អេច ខេ អេស អេ លីមីតធីត**
**HKSA., Limited**

**សមាគមបុគ្គលិកហត្ថាកសិករ (HK SA)** សមាគមបុគ្គលិកហត្ថាកសិករ គឺជានីតិបុគ្គលដែលទទួលបានហិរញ្ញវត្ថុពីបុគ្គលិកហត្ថាកសិករទាំងអស់។ រាល់បុគ្គលិកហត្ថាកសិករទាំងអស់ត្រូវបានអនុញ្ញាតអោយទិញភាគហ៊ុនរបស់ ហត្ថាកសិករ ក្នុងអំឡុងពេល ជាក់លាក់ណាមួយ (ជាទូទៅចាប់ពីខែមេសា ដល់ខែកញ្ញារៀងរាល់ឆ្នាំ)។ ទំហំនៃភាគលាភដែលផ្តល់ ដល់បុគ្គលិកក្នុងនាមជាភាគទុនិកអាស្រ័យលើប្រាក់ចំនេញសុទ្ធរបស់ហត្ថាកសិករ។ ជាទូទៅ គិតត្រឹមចុងឆ្នាំ២០១៤ ភាគហ៊ុនរបស់សមាគមបុគ្គលិកហត្ថាកសិករ នៅក្នុងក្រុមហ៊ុន ហត្ថាកសិករ លីមីតធីត មានចំនួន ៤៦៩,៣៩៨ដុល្លារអាមេរិក ដែលស្មើនឹង ៨,៩០% នៃភាគហ៊ុនសរុប។

## DR. DY DAVUTH

**បណ្ឌិត ឌី ដាវុធ (ឯកជន)** លោក ឌី ដាវុធ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ ជាតិគ្រប់គ្រង ក្នុងឆ្នាំ១៩៩៥ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០០១ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យ Utara Malaysia នៃប្រទេសម៉ាឡេស៊ី។ នៅដើមឆ្នាំ២០០៥ លោកទទួលបានសញ្ញាបត្រ ថ្នាក់បណ្ឌិតផ្នែកទស្សនវិជ្ជាពីសាកលវិទ្យាល័យ Rutherford (សិក្សាពីចម្ងាយ) នៅរដ្ឋ Wyoming សហរដ្ឋអាមេរិក។ ជាងនេះទៅទៀត លោកមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងតួនាទីជាច្រើនដូចជា ប្រធានគណនេយ្យ និងរដ្ឋបាល នៅJVK NAGA MOVERS បន្ទាប់មកជាប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ នៅស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ក្រោយមកទៀត លោក ឌី ដាវុធគឺជាសមាជិកគណៈកម្មការសំរបសំរួលគំរោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB និងជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យបៀលប្រាយ ព្រមទាំងជាប្រធានក្រុមប្រឹក្សាកម្មវិធីសិក្សានៃសាកលវិទ្យាល័យខាងលើនេះផងដែរ។ លើសពីនេះទៀត លោកជាអ្នកឯកទេសផ្នែកអភិវឌ្ឍន៍ពាណិជ្ជកម្មនៅក្រុមហ៊ុន SMEC International Pty. Ltd និងជាអ្នកសម្របសម្រួល និងទីប្រឹក្សាហិរញ្ញវត្ថុអោយក្រុមហ៊ុនHLSP-Mott Macdonald Group (គម្រោងWB)។ បន្តមកទៀត លោកបំពេញតួនាទីជាអ្នកជំនាញហិរញ្ញវត្ថុរបស់ Maxwell Stamp ដែលជាគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង បច្ចុប្បន្នជាលោកជានាយករងថ្នាក់ក្រោយបរិញ្ញា។

# រចនាសម្ព័ន្ធក្រុមហ៊ុន



# ក្រុមប្រឹក្សាភិបាល



## លោក Erik Peter Geurts, ប្រធានក្រុមប្រឹក្សាភិបាល

Erik Peter Geurts គាត់បានចូលរួមជាមួយក្រុមម្ចាស់ទ្រព្យដែលផ្តល់ហិរញ្ញប្បទានដល់ស្ថាប័នហិរញ្ញវត្ថុនៃ responAbility នៅក្នុងឆ្នាំ២០១៣ ។ គាត់មានបទពិសោធន៍ ១៧ឆ្នាំនៅក្នុងការអភិវឌ្ឍន៍ហិរញ្ញវត្ថុ ដែល តួនាទីចុងក្រោយមុនពេលគាត់ចូលរួមជាមួយ responAbility លោកជា អ្នកគ្រប់គ្រងទ្រព្យម្ចាស់នៃមូលនិធិ ស្ថាប័នមីក្រូហិរញ្ញវត្ថុ Triple Jump។ Erik គឺមានសកម្មភាពសំខាន់ជាច្រើននៅក្នុងតំបន់អាស៊ី ក្នុងរយៈពេល ៦ ឆ្នាំដែលលោកបំរើការងារនៅ Triple Jump។ លើសពីនេះ គាត់ធ្លាប់បម្រើការងាររយៈពេល ៩ឆ្នាំ នៅ Throdos ដែលនៅពេលនោះគាត់ជាអ្នកជំនាញក្នុងការផ្តល់ឥណទាន និងវិនិយោគទៅលើទ្រព្យម្ចាស់នៅអាមេរិកឡាទីន។ ក្នុងអាជីពរបស់គាត់ Erik បានធ្វើការជាក្រុមប្រឹក្សាភិបាលចំនួន ៨លើក ។ ក្នុងនោះមាន ៧ លើក គាត់ជាក្រុមប្រឹក្សាភិបាលអោយស្ថាប័នហិរញ្ញវត្ថុដែលមានសិទ្ធិទទួលប្រាក់បញ្ញើ និងជាធនាគារ ឯកទេស ព្រមទាំងធនាគារពាណិជ្ជ។



## លោក Christoffer Christensen-RØed, សមាជិកក្រុមប្រឹក្សាភិបាល

លោក Christoffer បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលអាជីវកម្មក្នុងឆ្នាំ១៩៦៦ នៅ Norges Handelshoyskole នៃប្រទេសន័រវេ។ លោក Christoffer បានចូលបំរើការងារនៅ Norfund ក្នុងឆ្នាំ២០០១ ហើយបច្ចុប្បន្ននេះលោក គឺជានាយកនាយកដ្ឋានវិនិយោគស្ថាប័នហិរញ្ញវត្ថុ និងមូលធិនិនៃ Norfund ដែលជាមូលនិធិវិនិយោគសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍របស់ប្រជាជាតិន័រវេ។ លោកមានបទពិសោធន៍ផ្នែកវិនិយោគយ៉ាងទូលំទូលាយ ក្នុងវិស័យធនាគារ និងស្ថាប័នហិរញ្ញវត្ថុនៅក្នុងទីផ្សារនៃប្រទេសកំពុងអភិវឌ្ឍន៍ ហើយលោកបានតំណាងឱ្យ Norfund ក្នុងតួនាទីជាក្រុមប្រឹក្សាភិបាលសំរាប់ស្ថាប័នជាច្រើនផងដែរ។ លោក Christoffer បានកាន់តួនាទីជាគណៈគ្រប់គ្រងជាច្រើននៅក្នុងអាជីវកម្មធនាគារពាណិជ្ជជាពិសេសផ្នែកឥណទាន និងទុនវិនិយោគទ្រព្យម្ចាស់ចាប់តាំងពីឆ្នាំ ១៩៦៦ មក។ នៅឆ្នាំ ១៩៨០ លោកត្រូវបានតែងតាំងជាអគ្គនាយកនៃធនាគារ Den Norske Credit bank ដែលជាធនាគារពាណិជ្ជ ធំជាងគេនៅក្នុងប្រទេសន័រវេ។ នៅចន្លោះឆ្នាំ១៩៧៧-១៩៨០ លោក Christoffer បានកាន់មុខតំណែងជាអនុប្រធានតំបន់អាស៊ីប៉ាស៊ីភិចនៃធនាគារ Nordic Bank Ltd នៅក្នុងប្រទេសសិង្ហបុរី ។



## លោក ឌី ដារុធ, សមាជិកក្រុមប្រឹក្សាភិបាល

លោក ឌី ដារុធ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលអាជីវកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលមានទីតាំងនៅរាជធានីភ្នំពេញក្នុងឆ្នាំ១៩៩៥ ។ ក្នុងឆ្នាំ២០០១ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលជំនួញនៅសាកលវិទ្យាល័យ Ultra នៃប្រទេសម៉ាឡេស៊ី។ក្នុងឆ្នាំ២០០៥លោកទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកទស្សនវិជ្ជាពីសាកលវិទ្យាល័យ Rutherford នៃសហរដ្ឋអាមេរិក។ លោកធ្លាប់មានបទពិសោធន៍ក្នុងតួនាទីជាច្រើនដូចជា ជាប្រធានគណនី និងរដ្ឋបាល នៅ JVK NAGA MOVERS និងជាប្រធានរដ្ឋបាល និង ហិរញ្ញវត្ថុ នៅស្ថាប័នមីក្រូហិរញ្ញវត្ថុដែលនាំមុខគេមួយក្នុងប្រទេសកម្ពុជា ។ ក្រោយមកទៀត លោកឌីដារុធ គឺជាសមាជិកគណៈកម្មាធិការសំរបសំរួលគំរោងនៃធនាគារអភិវឌ្ឍន៍អាស៊ី និងជា សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យបៀលប្រាយ ព្រមទាំងជាប្រធានក្រុមប្រឹក្សាផ្នែកកម្មវិធីសិក្សានៃ សាកលវិទ្យាល័យខាងលើផងដែរ និងធ្លាប់ជាអ្នកជំនាញផ្នែកអភិវឌ្ឍន៍អាជីវកម្មរបស់ SMEC International Pty Ltd និងជាអ្នកសម្របសម្រួល និងទីប្រឹក្សាហិរញ្ញវត្ថុអោយក្រុមហ៊ុន HLSP-Mott Macdonald Group ( គម្រោងWB )។ បន្តមកទៀត លោកបំពេញតួនាទីជាអ្នកជំនាញហិរញ្ញវត្ថុរបស់ Maxwell Stamp ដែលជាគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង បច្ចុប្បន្នជាលោកជានាយករងថ្នាក់ក្រោយបរិញ្ញា។



## លោក Eelco Mol, សមាជិកក្រុមប្រឹក្សាភិបាល

លោក Eelco បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចនៅឆ្នាំ១៩៩៥ ពីសាកលវិទ្យាល័យ Wageningen ប្រទេសហូឡង់ ។ Eelco គឺជាអ្នកគ្រប់គ្រងវិនិយោគទុនរបស់ Triple Jump ដែលបច្ចុប្បន្នលោកជាប្រធានបំណុលវិនិយោគ។ លោកជាសមាជិកក្រុមប្រឹក្សាភិបាលនៃស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើននៃប្រទេស Peru និង Mexico ។ ជាមួយនឹងសក្តានុពលដ៏ធំធេងនេះ Eelco ធ្វើការជាច្រើនប្រទេសនៅក្នុងពិភពលោក ដែលមានដូចជា ប្រទេសហូឡង់ Ghana, Honduras និង CostaRica។ ជាងនេះទៅទៀត Eelco មានបទពិសោធន៍ ជំនាញការងារជាច្រើនរួមមាន អ្នកគ្រប់គ្រងតំបន់ និងអ្នកគ្រប់គ្រងវិនិយោគជាន់ខ្ពស់នៅ Triple Jump មន្ត្រីវិនិយោគនៅ Oxfam Novib មន្ត្រីសមាគមវិជ្ជាជីវៈនៅ FAO អ្នកប្រឹក្សាយោបល់របស់ CDR និងអ្នកស្រាវជ្រាវ សមាគមផ្នែកសេដ្ឋកិច្ចរបស់សាកលវិទ្យាល័យ Wageningen ។



## លោក Tor G. Gull, សមាជិក

លោក Tor ទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យពីប្រទេសហ្វាំងឡង់ និងផ្នែកហិរញ្ញវត្ថុ និងអាជីវកម្ម អន្តរជាតិពីប្រទេសហ្វាំងឡង់ និងអាមេរិច។ តាំងពីការចូលនិវត្តន៍របស់គាត់ជានាយកប្រតិបត្តិ Oikocredit នៃប្រទេសហូឡង់នៅឆ្នាំ២០១១ លោក Torបានបន្តការទំនាក់ទំនងនៅផ្នែកអភិវឌ្ឍហិរញ្ញវត្ថុតាមរយៈកិច្ចការ រយៈពេលខ្លី និងជាសមាជិកក្រុមប្រឹក្សាភិបាល។ បទពិសោធន៍ពីមុនរបស់លោកទាំង ៤ឆ្នាំ នៅក្នុងការងារ អភិវឌ្ឍន៍នៅ Tenzania និង Kenya ហើយ ១៤ឆ្នាំនៅធនាគារប្រទេសហ្វាំងឡង់ ។ ក្នុងកំឡុងពេលនេះគាត់គឺជាប្រធានតំណាងនៃធនាគាររយៈពេល ៣ឆ្នាំ នៅតំបន់អាស៊ីអាគ្នេយ៍ និងចិនមានទីតាំងនៅហុងកុង ។



## **លោក ឡូញ ហៃ,** សមាជិកក្រុមប្រឹក្សាភិបាល

លោក ឡូញ ហៃ បានចូលនិវត្តន៍នៅខែតុលា ឆ្នាំ២០០៨ បន្ទាប់ពីបំរើការងារនៅធនាគារជាតិនៃកម្ពុជាអស់រយៈពេលជាង ២៥ឆ្នាំ។ លោកបានកាន់មុខតំណែងចុងក្រោយ ជា អគ្គនាយករង និងជាទីប្រឹក្សានៃ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា។ អំឡុងពេលបំពេញការងារនៅ ធនាគារជាតិនៃកម្ពុជា លោកបានធ្វើការងារនៅក្នុងនាយកដ្ឋាននានាជាច្រើន និងធ្វើការងារទាក់ទងនឹងសកម្មភាពផ្នែកហិរញ្ញវត្ថុទាំងក្នុងតំបន់ និងអន្តរជាតិ ដែលទាំងនេះបានធ្វើឲ្យ លោកទទួលបានបទពិសោធន៍ជាច្រើនទាក់ទងនឹងការងាររបស់ខ្លួន។ លើសពីនេះ លោក ឡូញ ហៃ បានចំណាយពេលវេលារបស់ខ្លួនក្នុងការរៀបចំបោះពុម្ពផ្សាយ ព្រឹត្តិប័ត្រ ស្ថិតិរូបិយវត្ថុ និងជញ្ជីងទូទាត់ជាច្រើននៅធនាគារជាតិនៃកម្ពុជា។ លោកធ្លាប់បានសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅមុនសម័យសង្គ្រាម ព្រមទាំងបានចូលរួមក្នុងវគ្គសិក្សាជាច្រើននៅក្រៅប្រទេសរួមមាន អ៊ីតាលី បារាំង អូទ្រីស និងសហរដ្ឋអាមេរិក។



## **លោកស្រី តាល់ ណៃអ៊ីម,** សមាជិកក្រុមប្រឹក្សាភិបាល

លោកស្រី តាល់ ណៃអ៊ីម បានចូលនិវត្តន៍នៅឆ្នាំ ២០១០ បន្ទាប់ពីលោកស្រីបានធ្វើការអស់រយៈពេល ៣០ឆ្នាំ ផ្នែកសេវាកម្មនៅធនាគារជាតិនៃកម្ពុជា ព្រមទាំងធនាគារពាណិជ្ជផងដែរ។ តួនាទីរបស់លោកស្រីចុងក្រោយ គឺជានាយិកាគ្រប់គ្រងទូទៅសំរាប់ ០៤ នាយកដ្ឋានសំខាន់ៗ ដូចជាអគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានប្រតិបត្តិការ អគ្គនាយកដ្ឋានស្ថិតិ និងស្រាវជ្រាវសេដ្ឋកិច្ច និងអគ្គនាយកដ្ឋានប្តូររូបិយប័ណ្ណបរទេស។ លោកស្រី តាល់ ណៃអ៊ីម បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពី សាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅប្រទេសកម្ពុជាឆ្នាំ១៩៧៤ ។ លោកស្រីបានចូលរួមបណ្តុះបណ្តាលវគ្គពិសេសជាច្រើនទៀតនៅក្រៅប្រទេស។



## **លោក ប៉ាក់ សេរីវឌ្ឍនា,** សមាជិកក្រុមប្រឹក្សាភិបាល

លោកប៉ាក់សេរីវឌ្ឍនា ( កើតនៅឆ្នាំ ១៩៧០ ) បានបញ្ចប់អនុបណ្ឌិត ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ( MFM ) នៅក្នុងឆ្នាំ១៩៩៧ ពីសាកលវិទ្យាល័យ Central Queenland អូស្រ្តាលី និងបរិញ្ញាបត្រសេដ្ឋកិច្ចពីវិទ្យាស្ថានសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៩២ ។ បច្ចុប្បន្នលោកជាអ្នកពិគ្រោះយោបល់នៃIFC និងជាទីប្រឹក្សាផ្នែកអាជីវកម្មមួយចំនួននៅប្រទេសកម្ពុជា និង Axis Investment Consulting ។ លោកវឌ្ឍនា មានបទពិសោធន៍ជាង ១៥ឆ្នាំនៃជំនាញវិជ្ជាជីវៈនៅក្នុងការគ្រប់គ្រងអាជីវកម្មនិងហិរញ្ញវត្ថុជាមួយអង្គការអន្តរជាតិនិងក្រុមហ៊ុនឯកជនជាច្រើន។ លោកបានបម្រើការងារនៅធនាគារពាណិជ្ជកម្ពុជា, British American Tobacco និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។

# គណៈគ្រប់គ្រង



## លោក ហួត អៀងតុង

### ប្រធានអគ្គនាយក

លោកឧកញ៉ា ហួត អៀងតុង មានបទពិសោធន៍ជាច្រើនលើវិស័យមីក្រូហិរញ្ញវត្ថុ ដែលជាកត្តាធ្វើឲ្យលោកក្លាយជាប្រតិបត្តិករយ៉ាងប៉ិនប្រសប់ទាំងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅក្នុងស្ថាប័ន។ លោកជាស្ថាបនិកម្នាក់ក្នុងចំណោមស្ថាបនិកនានារបស់ហត្ថាកសិករ ចាប់តាំងពីឆ្នាំ ១៩៩៦ និងតំណាងឲ្យអង្គការហត្ថាកសិករចាប់តាំងពីពេលនោះមក ។ លោកឧកញ៉ា ហួត អៀងតុង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រផ្នែកកសិកម្មនៅទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៩១ ។ លើសពីនេះទៅទៀត លោកធ្លាប់បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗជាច្រើនទាំងក្នុងនិងក្រៅប្រទេសលើមុខជំនាញរួមមាន គ្រប់គ្រងបុគ្គលិក គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងមីក្រូហិរញ្ញវត្ថុ គ្រប់គ្រងធនធានមនុស្ស ការធ្វើផែនការ និងភាពជាអ្នកដឹកនាំ។ លោកឧកញ៉ា ហួត អៀងតុង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលជំនួញពីសាកលវិទ្យាល័យបៀលប្រាយ ។ ពិសេសជាងនេះទៅទៀត លោកធ្លាប់ចូលរួមនៅក្នុងសិក្ខាសាលាជាច្រើនពាក់ព័ន្ធនឹងវិស័យមីក្រូហិរញ្ញវត្ថុនៅក្រៅប្រទេស ដែលរួមមានដូចជា ហ្វីលីពីន សហរដ្ឋអាមេរិក ឥណ្ឌូនេស៊ី បារាំង អាឡឺម៉ង់ និងប្រទេសជាច្រើនទៀត។



## កញ្ញា អ៊ឹម វណ្ណិត

### អនុប្រធានអគ្គនាយក និងជាអគ្គនាយិកាអភិបាលកិច្ច

កញ្ញា អ៊ឹម វណ្ណិត បានចាប់ផ្តើមអាជីពការងារក្នុងកំឡុងឆ្នាំ១៩៩២ ។ កញ្ញាបានចូលបំរើការងារនៅគណៈកម្មការផ្តល់ជំនួយរបស់សហរដ្ឋអាមេរិក (The American Relief Committee) បន្ទាប់ពីបំរើការងារជាបុគ្គលិកនៃ អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (UNTAC) កំឡុងការបោះឆ្នោតសភាជាតិក្នុងឆ្នាំ១៩៩២។ កញ្ញា អ៊ឹម វណ្ណិត បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញគណនេយ្យនៅឆ្នាំ ១៩៩៥ បន្ទាប់មកទៀត បានចូលបំរើការងារនៅហត្ថាកសិករក្នុងឆ្នាំ១៩៩៥។ កញ្ញាមានបទពិសោធន៍ការងារ ជាច្រើនលើវិស័យមីក្រូហិរញ្ញវត្ថុ ព្រមទាំងបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានាលើវិស័យនេះ និងវិស័យពាក់ព័ន្ធដទៃទៀតទាំងក្នុង និងក្រៅប្រទេស ដែលកត្តាទាំងអស់នេះហើយបានធ្វើឲ្យកញ្ញាក្លាយទៅជាអ្នកដើរតួនាទីសំខាន់ម្នាក់នៅក្នុងស្ថាប័ន។ កញ្ញា អ៊ឹម វណ្ណិត បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យបៀលប្រាយនៅខែសីហា ឆ្នាំ២០០៨។



## លោក ម៉ិច សុខមេត្រី

### អនុប្រធានអគ្គនាយក និងជាអគ្គនាយកអភិវឌ្ឍន៍អាជីវកម្ម

បន្ទាប់ពីចំណាយពេល៨ឆ្នាំនៅហត្ថាកសិករ ផ្នែកទីផ្សារ និងការគ្រប់គ្រងហានិភ័យ លោក មេត្រី ត្រូវបានដំឡើងតួនាទីជាអនុប្រធានអគ្គនាយក និងអគ្គនាយកអភិវឌ្ឍន៍អាជីវកម្ម នៅខែមករាឆ្នាំ២០១៤។ មុនចូលរួមជាមួយហត្ថាកសិករ នៅឆ្នាំ២០០៥ លោក មេត្រី មានបទពិសោធន៍ជាង ៣ឆ្នាំលើផ្នែកទីផ្សារ និងផ្នែកលក់ទាំងនៅតាមបណ្តាក្រុមហ៊ុនផលិតផល និងសេវាកម្មបន្ទាប់ពីលោកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង លើជំនាញទីផ្សារ។ នៅហត្ថាកសិករ ដោយបន្ថែមលើបទពិសោធន៍ក្នុងផ្នែកទីផ្សារនិងការគ្រប់គ្រងហានិភ័យ លោកមេត្រីបានចូលរួមវគ្គបណ្តុះបណ្តាលអនុវត្តន៍ជាច្រើន ដូចជាការគ្រប់គ្រងភាពជាអ្នកដឹកនាំ ការគ្រប់គ្រងផលិតភាព ការគ្រប់គ្រងទំនាក់ទំនងអតិថិជន balance scorecard ធានារ៉ាប់រងខ្នាតតូច និងជំនាញទីផ្សារដែលធ្វើឡើងទាំងក្នុង និងក្រៅប្រទេស ដែលរួមមានប្រទេសម៉ុងហ្គោលី តៃវ៉ាន់ កូរ៉េ ឥណ្ឌា និងឥណ្ឌូនេស៊ី។ ក្រៅពីនេះ លោក មេត្រី ត្រូវបានសាលាគ្រប់គ្រងនិងហិរញ្ញវត្ថុ Frankfurt ទទួលស្គាល់ថាជាអ្នកជំនាញផ្នែកគ្រប់គ្រងហានិភ័យ នៅឆ្នាំ 2013 ។



## លោក រដ្ឋ សារុណ

### អនុប្រធានអគ្គនាយក និងជាអគ្គនាយកហិរញ្ញវត្ថុ

លោក រដ្ឋ សារុណ មានបទពិសោធន៍ការងារផ្នែកបច្ចេកទេសជាង ១៣ ឆ្នាំ លើផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ នៅក្នុងស្ថាប័នហិរញ្ញវត្ថុនានាជាច្រើន និងឧស្សាហកម្មទូរគមនាគមន៍។ បច្ចុប្បន្ននេះ លោកមានភារៈកិច្ចទទួលខុសត្រូវលើការងារក្នុងនាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានរតនាភិបាលនៅហត្ថាកសិករ។ លោក រដ្ឋ សារុណ បានចូលបំរើការងារនៅហត្ថាកសិករក្នុងខែមិថុនាឆ្នាំ២០០៧ ក្នុងតួនាទីជាជំនួយការអគ្គនាយក ហើយបន្ទាប់មក ត្រូវបានដំឡើងតួនាទីជា អនុប្រធានអគ្គនាយក និងជាអគ្គនាយកហិរញ្ញវត្ថុក្នុងឆ្នាំ២០១១។ លោកមានបទពិសោធន៏ក្នុងអាជីពការងាររយៈពេល ៥ឆ្នាំ នៅធនាគារអេស៊ីលីដា ផ្នែកហិរញ្ញវត្ថុ និងរតនាភិបាល និងបទពិសោធន៍រយៈពេល ៣ឆ្នាំ ក្នុងតួនាទីជាប្រធានហិរញ្ញវត្ថុនៅក្រុមហ៊ុន AZ Communication Co.,Ltd. លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ និងបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗទាំងក្នុង និងក្រៅប្រទេសលើផ្នែកផ្សេងៗជាច្រើនរួមមានផ្នែកហិរញ្ញវត្ថុ គណនេយ្យ គ្រប់គ្រងហានិភ័យ និងផ្នែកព័ត៌មានវិទ្យា ។ល។



## លោក ទូច លីណា

### អនុប្រធានអគ្គនាយក និងជាអគ្គនាយកប្រតិបត្តិការ

លោក ទូច លីណា ត្រូវបានតែងតាំងជាអនុប្រធានអគ្គនាយក និងជាអគ្គនាយកប្រតិបត្តិការរបស់ហត្ថាកសិករនៅខែមីនា ឆ្នាំ២០១៣។ គាត់ទទួលខុសត្រូវរាល់ប្រតិបត្តិការអាជីវកម្មរបស់ហត្ថាកសិករ ដូចជាឥណទាន សន្សំ និងគ្រប់គ្រងសាខា។ គាត់បានចូលបំរើការងារនៅហត្ថាកសិករនៅខែមីនា ឆ្នាំ២០០៥ ដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងឥណទាន និងហានិភ័យមុនពេលលោកត្រូវបានតែងតាំងជានាយកហានិភ័យ និងប្រតិបត្តិតាមនៅឆ្នាំ ២០១១ ។ លោក ទូច លីណា បានពង្រីកចំណេះដឹង និងបទពិសោធន៍របស់គាត់យ៉ាងសស្រាក់សស្រាំដោយបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជាច្រើនទាំងនៅក្នុង និងក្រៅប្រទេសដូចជា ហ្វីលីពីន វៀតណាម និងលុចសំបើក។ មុនចូលរួមជាមួយហត្ថាកសិករ លោកចំណាយពេលជាងមួយឆ្នាំនៅអង្គការក្រៅរដ្ឋាភិបាលធ្វើការលើសេវាកម្មធានារ៉ាប់រងខ្នាតតូច ចំពោះប្រជាជនក្រីក្រទូទាំងតំបន់ជនបទក្នុងប្រទេសកម្ពុជា បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងនៅវិទ្យាស្ថានគ្រប់គ្រងឆ្នាំ២០០៣។



## អ្នកស្រី ខណ្ឌ បូនីដា

### ជំនួយការប្រធានអគ្គនាយក

លោកស្រី បូនីដា មានចំណេះដឹង និងជំនាញយ៉ាងទូលំទូលាយ ជាពិសេសខាងលទ្ធកម្មគ្រប់គ្រងការិយាល័យ ទូទាត់សំណង និងអត្ថប្រយោជន៍ យុទ្ធសាស្ត្រថែរក្សាបុគ្គលិក ការបណ្តុះបណ្តាល និងបង្កើនសមត្ថភាពបុគ្គលិក សុខុមាលភាពនយោជិត ច្បាប់ការងារ ទំនាក់ទំនងឧស្សាហកម្ម គោលនយោបាយ និងនីតិវិធីធនធានមនុស្ស ទំនាក់ទំនងទីផ្សារ និងប្រតិបត្តិការអាជីវកម្ម។ លោកស្រីបាន ចែករំលែក ចំណេះដឹង ជំនាញ និងបទពិសោធន៍ជាច្រើន តាមរយៈអាជីពក្នុងជីវិតរបស់គាត់ជាច្រើន ចាប់តាំងពីធ្វើការងារដំបូងក្នុងឆ្នាំ ២០០៣ ជាមួយនឹងក្រុមហ៊ុន Metro Group Cambodia ហើយក្រោយមក លោកស្រីបានចូលបំរើការងារជាមួយហត្ថាកសិករនៅឆ្នាំ២០០៥ ក្នុងតួនាទីខុសៗគ្នាជាច្រើនក្នុងផ្នែករដ្ឋបាល ធនធានមនុស្ស និងជាជំនួយការអនុប្រធានអគ្គនាយក និងអគ្គនាយិកាអភិបាលកិច្ច មុនពេលដែលលោកស្រីត្រូវបានតែងតាំងជាជំនួយការប្រធានអគ្គនាយកនៅខែមេសាឆ្នាំ ២០១៤។ លោកស្រី មានបរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ និង TEFL ព្រមទាំងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង និងបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលក្នុងស្រុកជាច្រើន។



## លោក បុង បិនលី

### នាយកបច្ចេកវិទ្យាព័ត៌មាន

លោក បុង បិនលី បានចូលបំរើការងារនៅហត្ថាកសិករ នៅខែធ្នូ ឆ្នាំ២០០២ ក្នុងតួនាទីជាអនុប្រធានអគ្គនាយក និងជានាយកបច្ចេកវិទ្យាព័ត៌មាន។ មុនពេលបំរើការងារជាមួយហត្ថាកសិករ លោកមានបទពិសោធន៍ការងារជាង ១០ឆ្នាំ លើផ្នែកព័ត៌មានវិទ្យាជាមួយនឹងគំរោងមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់កាណាដា។ លោកបានដើរតួនាទីយ៉ាងសំខាន់ម្នាក់នៅក្នុងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៅហត្ថាកសិករ ដោយសារតែបទពិសោធន៍ការងារដ៏ទូលំទូលាយលើជំនាញ និងឯកទេសរបស់គាត់។ ផ្សេងពីនេះទៅទៀត លោកធ្លាប់បាន ចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដើម្បីពង្រឹងបន្ថែមលើជំនាញ និងបទពិសោធន៍ផ្នែកបច្ចេកទេសរបស់គាត់ ដែលរួមមាន វគ្គបណ្តុះបណ្តាលលើជំនាញរដ្ឋបាលអាជីវកម្មទីផ្សារ គណនេយ្យ និងការគ្រប់គ្រង។ លោកនៅតែបន្តការសិក្សាលើផ្នែកព័ត៌មានវិទ្យាដើម្បីធ្វើអោយមានបច្ចុប្បន្នភាពបន្ថែមលើជំនាញរបស់ខ្លួនតាមរយៈការចូលរួមនៅក្នុងសន្និសីទ និងសិក្ខាសាលាជាច្រើនលើផ្នែក ICT និងបច្ចេកវិទ្យា Hardware និង Software ព្រមទាំងដំណោះស្រាយផ្នែកធនាគារនៅក្នុងប្រទេសកម្ពុជានិងប្រទេសជាច្រើនទៀតដូចជា ជប៉ុន ហុងកុង ម៉ាឡេស៊ី និងសហរដ្ឋអាមេរិកជាដើម។ លោកបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញបច្ចេកវិទ្យាព័ត៌មាននៅសាកលវិទ្យាល័យបៀលប្រាយ។



## លោក ជីន បូរាណច័ន្ទបូរ៉ាត់

### នាយកនីតិកម្ម និងលេខាធិការ

លោក ជីន បូរាណច័ន្ទបូរ៉ាត់ បានចូលបំរើការងារនៅហត្ថាកសិករនៅខែធ្នូឆ្នាំ២០១១ ក្នុងតួនាទីជានាយកនីតិកម្ម និងលេខាធិការ។ លោកមានបទពិសោធន៍ជាង ១០ឆ្នាំ នៅធនាគារអេស៊ីលីដា និងបុត្រសម្ព័ន្ធរបស់ ធនាគារអេស៊ីលីដាក្នុងប្រទេសឡាវ ដែលក្នុងរយៈពេល ៤ឆ្នាំចុងក្រោយ គាត់មានតួនាទីជាប្រធាននាយកដ្ឋាននីតិកម្ម និងលេខាធិការនៃបុត្រសម្ព័ន្ធរបស់ធនាគារអេស៊ីលីដាក្នុងប្រទេសឡាវ។ លោក ច័ន្ទបូរ៉ាត់ បានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រនីតិឯកជនពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចនៅឆ្នាំ២០០០ ហើយបច្ចុប្បន្ននេះ លោកកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្រ្តនៅសាកល វិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។



## អ្នកស្រី អ៊ិន សុជាតា

### នាយិការតនាភិបាល

លោកស្រីអ៊ិនសុជាតាបានចូលបំរើការងារនៅហត្ថាកសិករនៅឆ្នាំ២០០១។ លោកស្រីធ្លាប់មានតួនាទីជាច្រើន ទាំងនៅកំរិតសាខា និងការិយាល័យកណ្តាលនៅហត្ថាកសិករ។ ក្នុងឆ្នាំ២០០៧ លោកស្រីត្រូវបានតែងតាំងជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ បន្ទាប់មកជាប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុក្នុងឆ្នាំ២០០៨។ ក្រោយមកទៀតដោយផ្អែកលើចំណេះដឹងជំនាញ និងបទពិសោធន៍ លោកស្រីត្រូវបានតែងតាំងជានាយករងហិរញ្ញវត្ថុ នៅឆ្នាំ២០០៩។ នៅឆ្នាំ២០១២ លោកស្រីត្រូវបានតែងតាំងជានាយិការតនាភិបាល។ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យនៅឆ្នាំ២០០៧ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុពីសាកលវិទ្យាល័យបៀលប្រាយក្នុងឆ្នាំ២០១១។ លើសពីនេះលោកស្រីបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជាច្រើនរួមមានការធ្វើគម្រោងថវិកាវិភាគហិរញ្ញវត្ថុ គោលការណ៍គណនេយ្យ និងហិរញ្ញវត្ថុនៅក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុ វាយតម្លៃឥណទានសវនកម្មផ្ទៃក្នុងហិរញ្ញវត្ថុពាណិជ្ជកម្មនិងមុខវិជ្ជាផ្សេងៗទៀត។



## លោក កែវ គឹមហ៊ុត

### នាយកម៉ាឃីតធីង

លោក កែវ គឹមហ៊ុត បានចូលរួមជាមួយហត្ថាកសិករនៅខែមីនា ឆ្នាំ២០១២ ជានាយករងម៉ាឃីតធីង។ ដោយយោងទៅលើចំណេះដឹង និងបទពិសោធន៍ដ៏ទូលំទូលាយរបស់លោក លោកត្រូវបានតែងតាំងជានាយកម៉ាឃីតធីងនៅខែមករា ឆ្នាំ២០១៣។ មុនធ្វើការនៅហត្ថាកសិករ គាត់មានបទពិសោធន៍ជិត ៦ឆ្នាំនៅវិស័យមីក្រូហិរញ្ញវត្ថុ លើផ្នែកស្រាវជ្រាវទីផ្សារ និងការអភិវឌ្ឍន៍ផលិតផលហិរញ្ញវត្ថុ ទាំងផលិតផលឥណទាន និងមិនមែនឥណទាន។ លោកទទួលបានបរិញ្ញាបត្រផ្នែកសង្គមនៅឆ្នាំ២០០៥ ។ ដើម្បីបំពេញបន្ថែមលើចំណេះដឹង និងជំនាញ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងជំនាញលើវិស័យហិរញ្ញវត្ថុ និងធនាគារទាំងនៅក្នុង និងក្រៅប្រទេស។ បច្ចុប្បន្នលោកកំពុងតែបន្តការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ លើជំនាញការគ្រប់គ្រងទីផ្សារ ។



## លោក លី ស៊ីវ៉ែន

### នាយកឥណទាន

លោក លី ស៊ីវ៉ែន ចូលរួមជាមួយហត្ថាកសិករតាំងពីខែឧសភា ឆ្នាំ២០០០។ លោកបានឆ្លងកាត់តួនាទីជាច្រើនដូចជា មន្ត្រីមូលដ្ឋាន ប្រធានសាខា និងនាយកគ្រប់គ្រងតំបន់ហើយលោកត្រូវបានតែងតាំងជានាយកឥណទាន នៅឆ្នាំ២០១១។ ក្រៅពីនេះ លោកមានបទពិសោធន៍ជាង ៨ឆ្នាំ ជាមួយនឹងធនាគារជាតិនៃកម្ពុជា ក្នុងខេត្តកំពង់ធំ និងមន្ទីរសាធារណការ និងដឹកជញ្ជូនក្នុងខេត្តសៀមរាប។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចក្នុងឆ្នាំ២០១០ និងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យខាងលើក្នុងឆ្នាំ២០១៣។



## លោក លាង គឹមហ៊ួត

### នាយកឥណទានសហគ្រាសខ្នាតតូច និងមធ្យម

លោក លាង គឹមហ៊ួត បានចូលរួមជាមួយហត្ថាកសិករ តាំងពីឆ្នាំ២០០៦ ក្នុងតួនាទីជាមន្ត្រីឥណទាន។ ដោយយោងទៅលើចំណេះដឹង និងបទពិសោធន៍ការងាររបស់លោក លោកត្រូវបានដំឡើងឋានៈនៅក្នុងសាខាជាបន្តបន្ទាប់ និងចុងក្រោយលោកត្រូវបានតែងតាំងជានាយកសាខាក្នុងឆ្នាំ២០១១។ នៅខែវិច្ឆិកា ឆ្នាំ២០១២ លោកគីមហ៊ួត ត្រូវបានតែងតាំងជាប្រធានឥណទានសហគ្រាសខ្នាតតូច និងមធ្យមនៅការិយាល័យកណ្តាល។ បន្ទាប់មក លោកត្រូវបានតែងតាំងជានាយកសហគ្រាសឥណទាន សហគ្រាសខ្នាតតូច និងមធ្យម នៅខែមករា ឆ្នាំ២០១៤។ លោក គីមហ៊ួត ទទួលបានបរិញ្ញាបត្រ ផ្នែកគណនេយ្យ នៅឆ្នាំ២០០៧ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យ បៀលប្រាយនៅឆ្នាំ២០១៣។ ជាងនេះទៅទៀត គាត់បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗជាច្រើនទៀត ដូចជា ការគ្រប់គ្រងសាខា ភាពជាអ្នកដឹកនាំ កម្ចីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមវិភាគឥណទានសហគ្រាសខ្នាតតូច និងមធ្យម ការធ្វើអោយប្រសើរឡើងនូវសេវាបម្រើអតិថិជន ការដោះស្រាយជាមួយអតិថិជនពិបាក និងការត្អូញត្អែរការដឹកនាំភាពវៃឆ្លាត។



## លោក អ៊ូ គឹមថុន

### នាយកប្រាក់បញ្ញើ-សន្សំ

មុនចូលរួមជាមួយហត្ថាកសិករនៅខែមករាឆ្នាំ២០០៨លោកអ៊ូ គីមថុន ចំណាយពេលជាង ៤ឆ្នាំនៅផ្នែកសណ្ឋាគារ ដោយមានតួនាទីជាជំនួយការអ្នកគ្រប់គ្រងកម្មវិធី ដែលទទួលខុសត្រូវលើការរៀបចំកម្មវិធី ការគ្រប់គ្រងបុគ្គលិក និងការថែរក្សាអតិថិជន។ គាត់បានចាប់ផ្តើម ជាមួយហត្ថាកសិករជាមន្ត្រីឥណទាន ហើយត្រូវបានតំឡើងជាប្រធានផ្នែកគ្រប់គ្រងឥណទាន ជាប្រធានសាខានៅខែសីហា ឆ្នាំ២០០៩ និងចុងក្រោយជានាយកប្រាក់បញ្ញើសន្សំនៅឆ្នាំ ២០១៣។ គាត់ទទួលបរិញ្ញាបត្រលើជំនាញគ្រប់គ្រងទូទៅ ព្រមទាំងចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា ការដឹកនាំ ការផ្តល់ឥណទានចំពោះសហគ្រាសខ្នាតតូចនិង មធ្យម ការគ្រប់គ្រងយុទ្ធសាស្រ្តជាក់ស្តែង ការដឹកនាំភាពឆ្លាតវៃ ការពង្រឹងនូវលទ្ធផលនៃការលក់ ជាដើម ។ គាត់បានបន្តថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យបៀលប្រាយ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ។



## លោក អ៊ុំ ជលសក្តិ

### នាយកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

លោក ជលសក្តិ ចូលរួមជាមួយហត្ថាកសិករនៅខែឧសភា ឆ្នាំ២០០៥ មានតួនាទីជាមន្ត្រីសវនកម្មផ្ទៃក្នុង។ ដោយសារចំណេះដឹងជំនាញ និងបទពិសោធន៍ លោកត្រូវបានតែងតាំងតួនាទីជានាយករងសវនកម្មផ្ទៃក្នុងនៅឆ្នាំ២០១០ និងជានាយកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម នៅឆ្នាំ២០១៤។ មុនចូលរួមជាមួយហត្ថាកសិករ លោកជលសក្តិ ចំនាយពេលជាង១ឆ្នាំ ជាមួយនឹងធនាគារ អេស៊ីលីដា ជាមន្ត្រីឥណទាន។ លោកទទួលបានបរិញ្ញាបត្រផ្នែកគណនេយ្យ នៅឆ្នាំ២០០៣ នៅវិទ្យាស្ថានជាតិគ្រប់គ្រង និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យបៀលប្រាយនៅឆ្នាំ២០១១។ ជាងនេះទៅទៀត គាត់បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗទៀតជាច្រើនដូចជា ជំនាញសវនកម្មជាន់ខ្ពស់ សវនកម្មលើផ្នែកព័ត៌មានវិទ្យាសវនកម្មឥណទានជាក់ស្តែង ការពារការកេងបន្លំ ការគ្រប់គ្រងហានិភ័យ, CoOperacy អំណាចនៃភាពជាអ្នកដឹកនាំ ការដឹកនាំដោយភាពវៃឆ្លាតជាដើម។



## លោកស្រី អ៊ុក ម៉ាលីនី

### នាយិកាហិរញ្ញវត្ថុ

លោកស្រី អ៊ុក ម៉ាលីនី ចូលរួមជាមួយហត្ថាកសិករនៅខែតុលា ឆ្នាំ២០១២ ជានាយករងហិរញ្ញវត្ថុ និងត្រូវបានតែងតាំងជានាយិកាហិរញ្ញវត្ថុ នៅខែឧសភា ឆ្នាំ២០១៣។ មុនធ្វើការនៅហត្ថាកសិករ លោកស្រីបានចំណាយពេល ៧ឆ្នាំ នៅ KPMG Cambodia Ltd. ដែលធ្វើការទៅលើសវនកម្មនៃអាជីវកម្ម រោងចក្រ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារ ធានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត បន្ទាប់ពីលោកស្រីបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែករដ្ឋបាលអាជីវកម្ម ផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យ ន័រតុន នៅឆ្នាំ២០០៥។ ជាងនេះទៅទៀត លោកស្រីទទួលបានសញ្ញាបត្របញ្ជាក់ពីបច្ចេកទេសគណនេយ្យ និងសវនករនៅឆ្នាំ២០០៧ និងសញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យពី CamEd Business School នៅដើមឆ្នាំ២០១៣។ បច្ចុប្បន្ន លោកស្រីបានបន្តការសិក្សាលើ ACCA បន្ថែមទៀត ។



## លោក ផាត តូម៉ាស់

### នាយករដ្ឋបាល

លោក ផាត តូម៉ាស់ បានចាប់ផ្តើមអាជីពការងារក្នុងតួនាទីជាប្រធាននាយកដ្ឋានរដ្ឋបាលនៅស្ថាប័នមីក្រូហិរញ្ញវត្ថុហត្ថាកសិករក្នុងឆ្នាំ២០០៩ បន្ទាប់ពីបានបំពេញការងារនៅក្រុមហ៊ុនមួយ ក្នុងមុខតំណែងជាប្រធានធនធានមនុស្សអស់មួយរយៈពេលមក។ ជាការពិតលោកបានបំរើការងារនៅ ហត្ថាកសិកររយៈពេល ៤ឆ្នាំ និងមានបទពិសោធន៍ការងារជាង ៥ឆ្នាំនៅក្នុង វិស័យមីក្រូហិរញ្ញវត្ថុផ្នែករដ្ឋបាល និងធនធានមនុស្ស។ លោក ផាតតូម៉ាស់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើនដែលរួមមាន ការគ្រប់គ្រងបុគ្គលិក ភាពជាអ្នកដឹកនាំ ការទំនាក់ទំនង រដ្ឋបាល និងការគ្រប់គ្រងធនធានមនុស្ស។ បន្ថែមពីលើនេះលោកបានចូលរួមវគ្គបណ្តុះបណ្តាលនៅហ្វីលីពីនស្តីពីការឆ្លុះបញ្ចាំងធនធានមនុស្សនិងនៅជប៉ុនលើការអភិវឌ្ឍន៍សហគ្រាសខ្នាតតូចនិងមធ្យម។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រង។



## លោក ផាន សុវិទ្យា

### នាយកអេធីអឹម និងធនាគារចល័ត

លោក សុវិទ្យា ចូលរួមជាមួយហត្ថាកសិករនៅខែមេសា ឆ្នាំ២០០៥ ជានាយករងផ្នែកព័ត៌មានវិទ្យា ហើយលោកបានទទួលតំណែងជាជំនួយការអ្នកគ្រប់គ្រងគម្រោងនៃសេវាអេធីអឹម និងសេវាធនាគារចល័តនៅ ឆ្នាំ២០១២ ហើយលោកត្រូវបានតំឡើងតួនាទីជានាយកអេធីអឹម និងធនាគារចល័តនៅឆ្នាំ២០១៤។ មុនចូលធ្វើការនៅហត្ថាកសិករ លោក សុវិទ្យា ចំណាយពេលជាង ២ឆ្នាំនៅក្នុងវិស័យ ICT រួមមាន ជាអ្នកបច្ចេកទេសក្នុងការអភិវឌ្ឍ Software និងអភិវឌ្ឍដំណោះស្រាយអាជីវកម្ម។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកគណនេយ្យនៅឆ្នាំ១៩៩៨និងទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្រ្តកុំព្យូទ័រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ២០០២ និងបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជាប្រព័ន្ធ Micro-banker, Oracle Flexcube ( ប្រព័ន្ធ Core Banking របស់ហត្ថាកសិករ ) Wincor ATM, BPC Smart-Vista Switch System ភាពជាអ្នកដឹកនាំជាដើម។ នៅឆ្នាំ២០១៤ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងសេដ្ឋកិច្ច ក្នុងផ្នែកហិរញ្ញវត្ថុ និងធនាគារ ។



## លោក រស់ វ៉ុល

### នាយកសវនកម្មផ្ទៃក្នុង

លោក រស់ វ៉ុល បានចូលបំរើការងារនៅហត្ថាកសិករនៅខែមករា ឆ្នាំ២០០៨ ក្នុងតួនាទីជាប្រធាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង។ មុនចូលបំរើការងារជាមួយហត្ថាកសិករ លោកមានបទពិសោធន៍ជាង៨ឆ្នាំនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុលើផ្នែកសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងសាខា។ ក្រៅពីមានបទពិសោធន៍ការងារជាក់ស្តែង លោក រស់វ៉ុល បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗដែលរួមមានសវនកម្មការគ្រប់គ្រងសាខាការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងក្នុងការផ្តល់ប្រាក់កម្ចីជាដើម។ លោករស់ វ៉ុល បាន បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យព្រីសស្តុន (Preston University)។ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ជំនាញគ្រប់គ្រងនៅសាកលវិទ្យាល័យ Maharishi Verdic University ក្នុងឆ្នាំ១៩៩៨។



## លោកសេម សោភ័ណ

### នាយកធនធានមនុស្ស

លោកសេម សោភ័ណ បានចូលបំរើការងារនៅហត្ថាកសិករនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ក្នុងតួនាទីជាប្រធាន នាយកដ្ឋានធនធានមនុស្ស។ លោកមានបទពិសោធន៍ការងារជាង ២៧ឆ្នាំ ក្នុងវិស័យផ្សេងៗរួមមាន ការគ្រប់គ្រងធនធានមនុស្សរយៈពេល ១៨ឆ្នាំ ការអភិវឌ្ឍន៍ស្ថាប័ន ភាពជាអ្នកដឹកនាំ និងការធ្វើផែនការធនធានមនុស្ស។ ការងារចុងក្រោយរបស់លោកមុនចូលរួមជាមួយហត្ថាកសិករ លោកធ្វើការជាអ្នកផ្តល់ប្រឹក្សាធនធានមនុស្ស និងរដ្ឋបាល សម្រាប់ SAMES ( ឱសថស្ថានកណ្តាល ) ក្រសួងសុខាភិបាលរដ្ឋាភិបាលប្រទេសទីម័រខាងកើត គម្រោងHSSP-SP ដែលស្ថិតក្រោមការផ្តល់ហិរញ្ញប្បទានពីធនាគារពិភពលោក ( Health Sector Strategic Planning-Support Project ) ។ លោក សោភ័ណ ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញអភិវឌ្ឍភាពជាអ្នកដឹកនាំ ពីសាកលវិទ្យាល័យ Eastern រដ្ឋ Philadelphia សហរដ្ឋអាមេរិកនិងទទួលបានបរិញ្ញាបត្រផ្នែកនីតិសាធារណៈពីសាកលវិទ្យាល័យន័រតុន ក្នុងទីក្រុងភ្នំពេញ នៃប្រទេសកម្ពុជា ។



## លោក ស៊ុន សារ៉ាង

### នាយកអភិវឌ្ឍន៍ផលិតផល

លោក ស៊ុន សារ៉ាង បានចូលរួមជាមួយហត្ថាកសិករនៅខែមករា ឆ្នាំ២០១១ ក្នុងតួនាទីជានាយករងនាយកដ្ឋានប្រតិបត្តិការ និងបន្ទាប់មកលោកត្រូវបានផ្លាស់ប្តូរតួនាទីជានាយករងនាយកដ្ឋានឥណទានវិញ។ មុនបំរើការងារនៅហត្ថាកសិករ លោក សារ៉ាង មានបទពិសោធន៍រយៈពេល១២ឆ្នាំនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុក្នុងតួនាទីជាមន្ត្រីឥណទាននិងប្រធានសាខា។ ក្នុងកំឡុងពេលធ្វើការរបស់គាត់ លោកសារ៉ាងបានចូលរួមវគ្គសិក្ខាសាលាជាច្រើន និងការបណ្តុះបណ្តាលដែលទាក់ទងនឹងការគ្រប់គ្រងប្រតិបត្តិការ គ្រប់គ្រងឥណទាន គ្រប់គ្រងសាខា ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង និងប្រតិបត្តិការធនាគារផ្សេងៗទៀត។ យោងតាមសមត្ថភាព និងគុណភាពនៃការងាររបស់គាត់ លោកសារ៉ាង ត្រូវបានតែងតាំងជានាយកអភិវឌ្ឍន៍ផលិតផល នៅខែមេសា ឆ្នាំ២០១៤ ។គាត់ទទួលបានបរិញ្ញាបត្រនៅឆ្នាំ២០០៤ និង បរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ២០១០ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ។

# ព័ត៌មានរបស់អតិថិជន

ហត្ថាកសិករ លីមីតធីត កំពុងធ្វើប្រតិបត្តិការនៅទូទាំងប្រទេស ហើយបុគ្គលិកទាំងអស់ខិតខំប្រឹងប្រែងបម្រើអតិថិជនទាំងនៅជនបទ និងទីក្រុងយ៉ាងខ្ជាប់ខ្ជួន។ ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនទាំងអស់របស់ខ្លួនដោយរួមបញ្ចូលទាំងសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ព្រមទាំងអតិថិជនជាឯកត្តជនផងនោះ ហត្ថាកសិករបានកែច្នៃ និងបង្កើត ផលិតផល និងសេវាកម្មជាច្រើនប្រភេទផ្សេងៗគ្នា។

អតិថិជនភាគច្រើនបានរៀបការ និងមានកូននៅក្នុងបន្ទុក ដែលពួកគេមានសមាជិកក្នុងគ្រួសាររបស់ខ្លួនជាមធ្យម៤.៧៦នាក់ខណៈពេលដែលជាមធ្យម២.៥៧ នាក់ ជាអ្នករកប្រាក់ចំណូលសំរាប់គ្រួសារ។ អតិថិជនរបស់ ហត្ថាកសិករភាគ ច្រើនគឺជាស្ត្រី ដោយសារពួកគេបានដើរ តួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រង និងចាត់ចែងសាច់ប្រាក់ក្នុងគ្រួសារ ហើយពួកគាត់ ភាគច្រើនជាអក្ខរជនដែលធ្លាប់ បានសិក្សា ចប់នៅកម្រិតអនុវិទ្យាល័យ។

ជាងនេះទៅទៀត អតិថិជនរបស់ ហត្ថាកសិករ គឺជាក្រុមអតិថិជន សកម្ម ហើយមានអាយុចន្លោះចាប់ពី២៦ ទៅ៥៥ឆ្នាំ ដែល អាចរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ គ្រួសារ និងទ្រទ្រង់អាជីវកម្មរបស់ពួក គេ ដែលភាគច្រើន ទទួលបានពីរបរកសិកម្ម ជំនួញ សេវាកម្ម កម្មករ រោងចក្រ និងមុខរបរ ផ្សេងៗ ទៀត ។



អតិថិជនរបស់យើងភាគច្រើនរស់នៅតាមតំបន់ជនបទ ដែលធ្វើអោយឥណទានខ្នាតតូច និងតូចបំផុតមានការពេញនិយមយ៉ាងខ្លាំងសម្រាប់ពួកគេ។ យ៉ាងណាមិញ ឥណទានខ្នាតមធ្យម និងខ្នាតធំ សមស្របបំផុតសំរាប់អតិថិជនដែលរស់នៅតាមទីក្រុង និងទីប្រជុំជននានា។ អតិថិជនពេញចិត្តនឹងវិធីសាស្ត្របង់រំលស់ប្រាក់ដើមប្រចាំខែជាជាងវិធីសាស្ត្របង់រំលស់ប្រាក់ដើមតាមដំណាក់កាល ( Balloon និង Semi-Balloon ) ពីព្រោះចំនួនដែលត្រូវបង់មានការថយចុះបន្តិចម្តងៗពីមួយខែទៅមួយខែ។



# ចំណែកទីផ្សារ

ការប្រកួតប្រជែងនៅលើទីផ្សារនាពេលបច្ចុប្បន្ន មានការរីកចម្រើនកាន់តែខ្លាំងឡើងៗជាបន្តបន្ទាប់ ដែលជាលទ្ធផលមានស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួន៣៩ និងធនាគារពាណិជ្ជចំនួន៣៥ កំពុងដំណើរការអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ពួកគេបាន ព្យាយាមចាប់យកចំណែកទីផ្សារតាមអ្វីដែលពួកគេអាចធ្វើទៅបាន ដោយមិនបានគិតគូរពីគុណភាពប្រតិបត្តិការ និងការការពារហានិភ័យនោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ហត្ថាកសិករគឺជាស្ថាប័នមួយដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារ ដែលមិនត្រឹមតែផ្តោតលើការរីកចម្រើនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងយកចិត្តទុកដាក់ថែរក្សាគុណភាពប្រតិបត្តិការរបស់ខ្លួន និងការពារហានិភ័យដែលអាចកើតមានឡើងផងដែរ។ ទោះជាយ៉ាងនេះក្តី យើងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីពង្រីកចំណែកទីផ្សារ ទាំងសេវាឥណទាន និងប្រាក់បញ្ញើសន្សំ ។ ដោយផ្អែកលើតារាងខាងក្រោម ចំណែកទីផ្សាររបស់ហត្ថាកសិករ មានការកើនឡើងខ្លាំងគួរអោយកត់សម្គាល់នៅឆ្នាំ២០១៤ ដោយហត្ថាកសិករដណ្តើមបានចំណែកទីផ្សារលើសម្ពាធឥណទាន ១២.៣៣% និង១៩.៣៦% លើសម្ពាធប្រាក់បញ្ញើសន្សំ។ចំពោះអតិថិជនហត្ថាកសិករបានស្រូបយក៥.៦៦%នៃអតិថិជនខ្ចីប្រាក់និង១៦.៩៨%នៃអតិថិជនដែលដាក់ប្រាក់បញ្ញើសន្សំ ។












# ផលិតផល និងសេវាកម្ម

## ផលិតផលឥណទាន



ឥណទាន គឺជាផលិតផលគោលរបស់ហត្ថាកសិករ មានផលិតផលឥណទានជាច្រើនប្រភេទដែលបានបង្កើតឡើងដើម្បីបំពេញបំណងអតិថិជន និងតម្រូវការរបស់អតិថិជន។

### ឥណទានទូទៅ

ជាឥណទាន សំរាប់អតិថិជនលក្ខណៈបុគ្គល សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច មធ្យម និងសហគ្រាសខ្នាតធំ ដែលមានគោលបំណងប្រើប្រាស់ឥណទានច្បាស់លាស់ ហើយមិនប្រឆាំងនឹងច្បាប់ជាតិ និងអន្តរជាតិ ដើម្បីបង្កើតអាជីវកម្មថ្មី និងពង្រីកនូវអាជីវកម្មដែលមានស្រាប់។ អតិថិជនទទួលបាននូវលក្ខខណ្ឌឥណទានសមស្រប ហើយពួកគាត់អាចខ្ចីឥណទានទៅតាមតំរូវការរហូតដល់ ២០០,០០០ដុល្លារអាមេរិកអាស្រ័យទៅតាមលទ្ធភាពនៃការសង។ ហត្ថាកសិករ ផ្តល់ឲ្យនូវអត្រាការប្រាក់ដែលមានការប្រកួតប្រជែង និងមានរយៈពេលវែងយោងទៅតាមខួបនៃអាជីវកម្ម និងលំហូរសាច់ប្រាក់របស់អតិថិជន។

### ឥណទានថែរក្សាអនាម័យ និងបរិស្ថាន

ជាឥណទានសម្រាប់អតិថិជនទាំងនៅតំបន់ជនបទ និងទីប្រជុំជនដែលមានគោលបំណងច្បាស់លាស់ដើម្បីបង្កើនកម្រិតជីវភាពរបស់ពួកគាត់ តាមរយៈឥណទានដើម្បីបង្កើតជាឡជីវឧស្ម័ន ការប្រើប្រាស់ពន្លឺព្រះអាទិត្យ ការទិញម៉ាស៊ីនចម្រោះ និងការសង់បង្គន់អនាម័យ ជាដើម។ អតិថិជនអាចខ្ចីទៅដល់ ២,៥០០ដុល្លារ ដែលមានរយៈពេលកម្ចីរយៈពេលពី០៣ ទៅ ២៤ខែ និងមានអត្រាការប្រាក់ដែលមានការប្រកួតប្រជែង អាស្រ័យលើរយៈពេល និងរូបិយប័ណ្ណនៃកម្ចី។

### ឥណទាននិស្សិតខ្មែរ

ឥណទាននេះត្រូវបានបង្កើតឡើងសម្រាប់ឳពុកម្តាយដែលចង់ផ្តល់ការសិក្សាអោយកូន ឬសិស្សដែលចង់បន្តការសិក្សាកម្រិតបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ ឬវគ្គបណ្តុះបណ្តាលផ្សេងៗ ប៉ុន្តែពួកគេមិនមានថវិកាគ្រប់គ្រាន់ក្នុងការគាំទ្រចំណាយក្នុងការសិក្សា និងការចំណាយផ្សេងៗទៀតសំរាប់ការសិក្សា។ អតិថិជនអាចខ្ចីបានរហូតដល់ ៨,០០០ដុល្លារ ដែលមានរយៈពេលពី៦ខែ ដល់៨៤ខែ ហើយអាចទទួលបានអត្រាការប្រាក់ដែលមានការប្រកួតប្រជែង អាស្រ័យលើទំហំឥណទាន និង

### ឥណទានសហគ្រាសខ្នាតតូច និងមធ្យម

ឥណទាននេះត្រូវបានផ្តល់ឱ្យទៅបុគ្គលឯកជន ឬនីតិបុគ្គលសាជីវកម្មដែលបានបើកអាជីវកម្មខ្នាតតូច និងមធ្យមហើយត្រូវការប្រាក់កម្ចីដើម្បីបង្កើត ឬពង្រីកអាជីវកម្មរបស់ខ្លួនបន្ថែមទៀត។ ឥណទាននេះអាចប្រើប្រាស់បានជាទុនបង្វិល ឬសំរាប់គោលបំណងវិនិយោគនានា។ ជាមួយគ្នានេះដែរ អតិថិជននឹងទទួលបានលក្ខខណ្ឌឥណទានដែលមានភាពងាយស្រួលនិងអាចបត់បែនបាន ហើយមានអត្រាការប្រាក់ទាបដោយផ្អែកលើលទ្ធភាពសង និងទំហំឥណទានរបស់ពួកគេ។ អតិថិជនអាចទទួលបានប្រាក់កម្ចីរហូតដល់ ២០០,០០០ ដុល្លារអាមេរិកឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត ជាមួយនឹងរយៈពេលវែងយោងទៅតាមខួបនៃអាជីវកម្ម។

### ឥណទានគេហដ្ឋាន ( ដំណាក់កាលសាកល្បង )

ឥណទាននេះត្រូវបានបង្កើតឡើងសម្រាប់បុគ្គលឯកជន ដែលមានបំណងចង់បង្កើនកម្រិតជីវភាពរបស់ពួកគាត់អោយបានប្រសើរជាងមុន តាមរយៈការសាងសង់គេហដ្ឋាន កែលម្អ ឬទិញគេហដ្ឋានថ្មី។ អតិថិជនអាចរីករាយជាមួយនឹងលក្ខខណ្ឌឥណទានដែលអាចបត់បែនបាន និងអត្រាការប្រាក់ដែលមានការប្រកួតប្រជែង។ អតិថិជនអាចទទួលបានប្រាក់កម្ចីរហូតដល់ ១០០,០០០ ដុល្លារអាមេរិកដោយយោងទៅតាមលទ្ធភាពនៃការសង និងរយៈពេលកម្ចី របស់ពួកគេដែលត្រូវបានផ្តល់ជូនរហូតដល់ទៅ ១២ ឆ្នាំ។ ឥណទាននេះត្រូវបានសាកល្បងដោយជោគជ័យនៅក្នុងទីផ្សារ ហើយកំពុងដំណើរការវាយតម្លៃ និងកែប្រែ ដែលរំពឹងថានឹងអាចដាក់លក់ជាផ្លូវការនៅ ឆ្នាំ២០១៥ ។

## ផលិតផលប្រាក់បញ្ញើសន្សំ




ដើម្បីបំពេញតម្រូវការរបស់អតិថិជន ហត្ថាកសិករបានបង្កើតផលិតផលប្រាក់បញ្ញើសន្សំយ៉ាងច្រើនប្រភេទរួមមាន គណនីសន្សំ គណនីបង្គរដើម និងគណនីបញ្ញើមានកាលកំណត់។

## គណនីសន្សំសំចៃ

គណនីនេះអនុញ្ញាតឱ្យអតិថិជនអាចដាក់ និងដកប្រាក់បានទៅតាមតម្រូវការនៅគ្រប់ការិយាល័យ និងគ្រប់ពេលវេលាតាមរយៈម៉ាស៊ីនអេធីអឹមរបស់ ហត្ថាកសិករ លីមីតធីត ។ គណនីសន្សំនេះ ជាមធ្យោបាយ ដ៏ប្រសើរបំផុតមួយដែលជួយឱ្យអតិថិជនបង្កើនប្រាក់ចំណូលទៅលើការសន្សំរបស់គាត់ និងទទួលបានសុវត្ថិភាពខ្ពស់។ អតិថិជនអាចបើកគណនីបានដោយគ្រាន់តែមានទឹកប្រាក់ចំនួន ៥ដុល្លារ ឬសមាមាត្រនឹងរូបិយប័ណ្ណផ្សេងៗ ហើយអតិថិជននឹងទទួលបាននូវអត្រាការប្រាក់ដែលមានលក្ខណៈប្រកួតប្រជែង ទៅតាមប្រភេទរូបិយប័ណ្ណដែលបានសន្សំ។ លើសពីនេះអតិថិជនត្រូវបានផ្តល់ជូនសៀវភៅប្រាក់សន្សំដោយឥតគិតថ្លៃនៅរាល់ពេលបើកគណនីនេះ។

## គណនីសន្សំវីអាយភី

គណនីនេះ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ស្ថាប័ន និងអតិថិជនសំខាន់ៗ មួយចំនួន។ ហត្ថាកសិករផ្តល់ជូននូវសេវាកម្មដ៏ល្អប្រសើរ និងយកចិត្តទុកដាក់ចំពោះអតិថិជនប្រភេទនេះ។ ការបើកគណនីនេះតម្រូវឱ្យអតិថិជនមានទឹកប្រាក់ដំបូងក្នុងគណនីចំនួន ៥០០ដុល្លារ ឬសមាមាត្រនឹងរូបិយប័ណ្ណផ្សេងទៀត។ ជាពិសេស ហត្ថាកសិករផ្តល់ជូនអត្រាការប្រាក់ខ្ពស់ដោយយោងទៅតាមប្រភេទរូបិយប័ណ្ណដែលបានដាក់សន្សំ។

## គណនីសម្រេចសុបិន

គណនីនេះ តម្រូវឱ្យអតិថិជនដាក់ប្រាក់សន្សំរបស់ខ្លួនតាមដំណាក់កាលដោយផ្អែកទៅតាមលំហូរសាច់ប្រាក់ដែលអាចដក់ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ នៅក្នុងពេលវេលាកំណត់ជាក់លាក់ណាមួយ។ ដើម្បីបើកគណនីនេះអតិថិជន គ្រាន់តែមានទឹកប្រាក់ដំបូងក្នុងគណនីចំនួន ១០ដុល្លារ ឬសមាមាត្រនឹងរូបិយប័ណ្ណផ្សេងប៉ុណ្ណោះ ដែលមានរយៈពេលបញ្ញើពី ៦ខែ ទៅ ៦០ខែ និងទទួលបាន អត្រាការប្រាក់ខ្ពស់ផ្អែកលើរយៈពេល និងប្រភេទរូបិយប័ណ្ណ។

## គណនីកូនខ្ញុំ

ជាប្រភេទគណនី ដែលអនុញ្ញាតអោយអតិថិជនជាឪពុកម្តាយ ឬអាណាព្យាបាលដាក់ប្រាក់សន្សំដើម្បីអនាគតកូន។ អតិថិជនអាចដាក់ប្រាក់សន្សំតាមដំណាក់កាលទៅតាមចរន្តសាច់ប្រាក់របស់ខ្លួន ដែលអាចសន្សំជាប្រចាំថ្ងៃ ប្រចាំ សប្តាហ៍ និង ប្រចាំខែ។ ដើម្បីបើកគណនីកូនខ្ញុំ អតិថិជនត្រូវមានប្រាក់សន្សំនៅក្នុងគណនីចំនួន១០ដុល្លារ ហើយមានរយៈពេលនៃការសន្សំប្រែប្រួលទៅតាមការជ្រើសរើសរបស់អតិថិជនចាប់ពី ២ឆ្នាំ ទៅ១៨ឆ្នាំ។ អតិថិជនអាចទទួលបានអត្រាការប្រាក់ខ្ពស់អាស្រ័យទៅតាមរយៈពេល និងរូបិយប័ណ្ណដែលបាន ដាក់សន្សំ ។

## គណនីនិវត្តន៍ជន

ជាប្រភេទគណនីដែលអនុញ្ញាតអោយអតិថិជនដែលជាបុគ្គលិកក្រុមហ៊ុន អង្គការ មន្ត្រីរាជការ ឬអ្នកដែលមានបំណងដាក់ប្រាក់សន្សំសំរាប់ការចូលចូលនិវត្តន៍។ គណនីនេះតម្រូវអោយអតិថិជន ធ្វើការដាក់ប្រាក់សន្សំ តាមដំណាក់កាលអាស្រ័យតាមលំហូរចំណូលរបស់អតិថិជនដែលអាចដាក់ប្រចាំថ្ងៃ ប្រចាំសប្តាហ៍និងប្រចាំខែ ។ដើម្បីបើកគណនីនេះអតិថិជនគ្រាន់តែដាក់ប្រាក់សន្សំ ២៥ដុល្លារ ក្នុងគណនី ហើយគាត់អាច ជ្រើសរើសរយៈពេលនៃការសន្សំ ពី២ឆ្នាំ ទៅ ១៨ឆ្នាំ។ អតិថិជនអាចទទួលបានអត្រាការប្រាក់ខ្ពស់ អាស្រ័យទៅ តាមរយៈពេល និងរូបិយប័ណ្ណនៃប្រាក់បញ្ញើ ។

## គណនីបញ្ញើកើនដើម

ជាប្រភេទគណនី បង្កើតឡើងសំរាប់អតិថិជនដែលមានសាច់ប្រាក់ទំនេរច្រើន ហើយចង់ទទួលបាននូវអត្រាការប្រាក់ខ្ពស់ត្រលប់ទៅវិញ។ ជាមួយនឹងគណនីនេះ ការប្រាក់ត្រូវបានគណនាជាប្រចាំថ្ងៃ ហើយនឹងផ្ទេរទៅជាប្រាក់ដើមដោយស្វ័យប្រវត្តិនៅរៀងរាល់ចុងខែ។ អតិថិជនគ្រាន់តែមានទឹកប្រាក់ចំនួន ៥០ ដុល្លារប៉ុណ្ណោះ ឬសមមាត្រ នឹងរូបិយប័ណ្ណផ្សេង សំរាប់បើកគណនី ហើយអតិថិជនអាចជ្រើសរើសរយៈពេលសន្សំ ពី១ខែ ទៅ ១២ខែ និងទទួលបានអត្រាការប្រាក់សមរម្យ អាស្រ័យទៅលើរយៈពេលនៃការដាក់ប្រាក់បញ្ញើ និង រូបិយប័ណ្ណប្រាក់បញ្ញើផងដែរ ។

## គណនីបញ្ញើកើនចំណូល

ជាប្រភេទគណនី បង្កើតឡើងសំរាប់អតិថិជនដែលមានសាច់ប្រាក់ទំនេរច្រើន ហើយចង់ទទួលបាននូវ អត្រាការប្រាក់ខ្ពស់ត្រលប់ទៅវិញ។ ជាប្រភេទគណនីដែលអតិថិជនអាចដកការប្រាក់បានរៀងរាល់ ខែនីមួយៗ ហើយមានការប្រាក់ខ្ពស់។ ដើម្បីបើកគណនីនេះ គាត់ត្រូវមានសាច់ប្រាក់នៅក្នុងគណនីចំនួន ៥០ដុល្លារ ឬសមមាត្រនឹងរូបិយប័ណ្ណផ្សេង ហើយអាចជ្រើសរើសរយៈពេលពី ១ខែ ទៅ ១២ខែ ហើយមានអត្រាការប្រាក់ដ៏ប្រសើរ អាស្រ័យទៅតាមរយៈពេល និងរូបិយប័ណ្ណនៃប្រាក់បញ្ញើ ។

## គណនីបញ្ញើកើនទ្រព្យ

ជាប្រភេទគណនី បង្កើតឡើងសំរាប់អតិថិជនដែលមានសាច់ប្រាក់ទំនេរច្រើន ហើយចង់ទទួលបាននូវ អត្រាការប្រាក់ខ្ពស់ត្រលប់ទៅវិញ។ អតិថិជនអាចប្រើប្រាស់គណនីនេះ ដោយអាចដកប្រាក់នៅចុងបញ្ចប់នៃវគ្គ ហើយដើម្បីបើកគណនីនេះ អតិថិជនគ្រាន់តែដាក់ប្រាក់នៅក្នុងគណនីចំនួន៥០ដុល្លារឬសមមាត្រនឹងរូបិយប័ណ្ណផ្សេងហើយអាចជ្រើសរើសរយៈពេលពី ១ខែ ទៅ ១២ខែ និងមានអត្រាការប្រាក់ខ្ពស់ អាស្រ័យលើរយៈពេល និងរូបិយប័ណ្ណនៃប្រាក់បញ្ញើ ។

## គណនីបញ្ញើសប្បុរសជន

ជាប្រភេទគណនីសំរាប់អតិថិជនដែលជាស្ថាប័ន ឬបវន្តបុគ្គលដែលមានសាច់ប្រាក់ច្រើនលើសពី សេចក្តីត្រូវការ ហើយមានទឹកចិត្តសប្បុរសជួយដល់អង្គការដែលមានចក្ខុវិស័យដូចគ្នា និងស្រដៀងគ្នា។ អតិថិជនគ្រាន់តែដាក់សាច់ប្រាក់នៅក្នុងគណនី ១,០០០ ដុល្លារ ហើយគាត់អាចជ្រើសរើសរយៈពេលពី ៣ខែ ទៅ ២៤ខែ និងមានអត្រាការប្រាក់ប្រចាំឆ្នាំដែលមានលក្ខណៈប្រកួតប្រជែងអាស្រ័យទៅតាមរយៈពេល និងរូបិយប័ណ្ណនៃប្រាក់បញ្ញើ ។

## សេវាកម្មផ្ទេរប្រាក់ក្នុងស្រុក



ហត្ថាកសិករ ផ្តល់ជូនអតិថិជនជាមួយនឹងដំណោះស្រាយដ៏ត្រឹមត្រូវសម្រាប់សេវាកម្មផ្ទេរប្រាក់ក្នុងស្រុក។ អតិថិជនមានភាពងាយស្រួលក្នុងការផ្ទេរប្រាក់ក្នុងស្រុក ទៅកាន់សាច់ញាតិ បងប្អូន ដៃគូពាណិជ្ជកម្ម ព្រមទាំងអ្នកជាទីស្រលាញ់ផ្សេងទៀត ប្រកបដោយភាពជឿជាក់ មានសុវត្ថិភាព និងរហ័សទាន់ចិត្ត។ ដូច្នេះ វាលែងជាបញ្ហាទៀតហើយក្នុងការផ្ទេរប្រាក់ទៅកាន់អ្នកជាទីស្រឡាញ់ ក្រុមគ្រួសារ ដៃគូពាណិជ្ជកម្ម និងសាច់ញាតិ បានទូទាំងប្រទេសកម្ពុជាជាមួយហត្ថាកសិករ ជាមួយនឹង ១៤២ កន្លែងនៅទូទាំង ២៥ ខេត្ត-រាជធានី និងមានកំរៃសេវាសមរម្យ។ ជាងនេះទៅទៀត មានវិធីសាស្រ្តក្នុងការផ្ទេរប្រាក់ជាច្រើនដែលអតិថិជនអាចជ្រើសរើសបានដូចជា ផ្ទេរពីសាច់ប្រាក់ ទៅសាច់ប្រាក់ ផ្ទេរពីសាច់ប្រាក់ទៅគណនី ផ្ទេរពីគណនីទៅសាច់ប្រាក់ និងផ្ទេរពីគណនីទៅគណនី ។

## សេវាម៉ាយអេធីអឹម



ជាមួយនឹងសេវាម៉ាយអេធីអឹមនេះ អតិថិជនអាចធ្វើប្រតិបត្តិការបានទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដូចជា ការដាក់ប្រាក់ ដកប្រាក់ ផ្ទេរប្រាក់ ផ្ញើប្រាក់ ប្តូរប្រាក់ ទិញកាតទូរស័ព្ទ ពិនិត្យសមតុល្យក្នុងគណនី ពិនិត្យរបាយការណ៍សង្ខេប ថែរក្សាគណនី និងបើកគណនីសន្សំ។ល។ ជាពិសេសអតិថិជនទាំងអស់អាចជ្រើសរើសរូបិយប័ណ្ណបីប្រភេទដូចជា ប្រាក់រៀលខ្មែរ ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ។ ជាងនេះទៅទៀត អតិថិជនអាចងាយស្រួលធ្វើប្រតិបត្តិការរបស់ពួកគាត់តាមរយៈម៉ាស៊ីនអេធីអឹមរបស់ហត្ថាកសិករពេញផ្ទៃប្រទេស។ អតិថិជននឹងទទួលបានកាតអេធីអឹមមួយដោយឥតគិតថ្លៃនៅពេលបើកគណនីសន្សំជាមួយហត្ថាកសិករថ្ងៃនេះ និងអាចប្រើប្រាស់សំរាប់ដាក់ប្រាក់ ឬដកប្រាក់បានគ្រប់ពេលវេលា។

## សេវាធនាគារចល័ត



សេវាធនាគារចល័ត ជាសេវាកម្មហិរញ្ញវត្ថុថ្មីមួយដែលអតិថិជន និងសាធារណជនអាចត្រួតពិនិត្យ ប្រតិបត្តិការហិរញ្ញវត្ថុរបស់ពួកគេគ្រប់ពេលវេលា និងគ្រប់ទីកន្លែងតាមរយៈទូរស័ព្ទដៃ។ តាមរយៈនេះ អតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុជាច្រើនដូចជា ផ្ញើប្រាក់ ផ្ទេរប្រាក់ ទិញកាតទូរស័ព្ទដៃ ទូទាត់វិក្កយបត្រ សងប្រាក់ឥណទាន និងប្រតិបត្តិការមិនមែនហិរញ្ញវត្ថុមួយចំនួនទៀតដូចជា ពិនិត្យសមតុល្យគណនី ពិនិត្យរបាយការណ៍សង្ខេប សារជូនដំណឹងជាអក្សរ ពិនិត្យអត្រាប្តូរប្រាក់ ពិនិត្យអត្រាការប្រាក់ ព័ត៌មានឥណទាន ការរំលឹកពីការសងឥណទាន និងធ្វើប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗទៀត។

## សេវាបើកប្រាក់បៀវត្សរ៍



សេវាបើកប្រាក់បៀវត្សត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលជាសហគ្រាស ក្រុមហ៊ុន អង្គការ ស្ថាប័នរដ្ឋ និងសមាគមទាំងឡាយណាដែលមានបំណងកាត់បន្ថយពេលវេលា និងបន្ទុកការងារក្នុងការគ្រប់គ្រងដំណើរការបើកប្រាក់បៀវត្សរ៍ដល់និយោជិតរបស់ពួកគេ។ តាមរយៈសេវាបើកប្រាក់បៀវត្សរ៍របស់ហត្ថាកសិករ និយោជិករបស់លោកអ្នកនឹងទទួលបាននូវភាពបត់បែនដ៏អស្ចារ្យ ភាពងាយស្រួល និងអត្ថប្រយោជន៍ជាច្រើនផ្សេងៗទៀត ក្នុងពេលជាមួយគ្នាដែរ ក្រុមហ៊ុន ឬស្ថាប័នរបស់លោកអ្នកនឹងទទួលបានការពេញចិត្តពីសំណាក់បុគ្គលិកកាន់តែខ្លាំងឡើងបន្ថែមទៀត។

## សេវាទូទាត់ និងប្រមូលសាច់ប្រាក់ ( ដំណាក់កាលសាកល្បង )

ដោយធ្វើកិច្ចសហការជាមួយធនាគារ ANZ Royal ហត្ថាកសិករបានដើរតួនាទីយ៉ាងសំខាន់ក្នុងនាមជាបណ្តាញទូទាត់ និងប្រមូលសាច់ប្រាក់សំរាប់ធនាគារ ANZ។ សេវានេះកំពុងដាក់ដំណើរការសាកល្បងនៅតាមសាខាចំនួន៥ដែលកំពុងបម្រើអតិថិជនធនាគារ ANZ ជាអាជីវករលក់ដុំ-រាយ សហគ្រាស ឈ្មួញ និងអ្នកផ្គត់ផ្គង់នានា។ ជាមួយនឹងសេវានេះ អតិថិជនរបស់ធនាគារ ANZ ទាំងអស់អាចធ្វើការទូទាត់សាច់ប្រាក់ជាមួយអ្នកផ្គត់ផ្គង់របស់ពួកគេ ឬប្រមូលប្រាក់ពីអ្នកលក់ដុំ-រាយ ។ល។ តាមរយៈការិយាល័យហត្ថាកសិករដែលនៅជិតពួកគេ ដែលធ្វើអោយពួកគេអាចកាត់បន្ថយពេលវេលា និងថ្លៃចំណាយក្នុងការធ្វើដំណើរទៅកាន់ការិយាល័យធនាគារ ANZ ដែលមិនទាន់មានក្នុងតំបន់ដែលគេកំពុងរស់នៅឡើយ។

## សេវាធានារ៉ាប់រងខ្នាតតូចលើសុខភាព និងអាយុជីវិត ( ដំណាក់កាលសាកល្បង )

ហត្ថាកសិករ បានចាប់ដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រង ប្រេវ័រ (កម្ពុជា) ម៉ាយក្រូ ឡាយហ្វ៍ អ៊ិនសួរេន ភីអីលសុី ( Prévoir Kampuchea Micro Life Insurance ) ដើម្បីផ្តល់សេវាធានារ៉ាប់រងលើសុខភាព និងអាយុជីវិតខ្នាតតូចបន្ថែមទៀតទៅដល់អតិថិជនប្រាក់សន្សំ និងអតិថិជនប្រាក់កម្ចីរបស់ហត្ថាកសិករ លីមីតធីត។ អតិថិជនគ្រាន់តែបង់ប្រាក់ធានាតិចតួចតែម្តងគត់នៅដើមកាលវិភាគឥណទានសំរាប់ការធានារយៈពេល១២ខែ នោះអតិថិជននឹងទទួលបានអត្ថប្រយោជន៍អតិបរមា ដែលធានាគ្របដណ្តប់លើថ្លៃចំណាយស្នាក់នៅក្នុងមន្ទីរពេទ្យសុខភាពសាធារណៈ ក្នុងករណីដែលមានជម្ងឺ ឬជួបគ្រោះថ្នាក់ជាយថាហេតុនៅក្នុងកំឡុងខួបនៃការធានា។

# ធនធានមនុស្ស



## ភាពជោគជ័យរបស់បុគ្គលិក គឺជាជោគជ័យរបស់ស្ថាប័ន

ភាពជោគជ័យរបស់ហត្ថាកសិករ គឺអាស្រ័យទៅលើការដឹកនាំ និងការប្រឹងប្រែងរបស់បុគ្គលិក។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ មុខជំនួញហត្ថាកសិករមានការរីកចម្រើនយ៉ាងខ្លាំង ដែលជាលទ្ធផលបានមកពីការដឹកនាំដ៏ត្រឹមត្រូវ និងបុគ្គលិកដែលមានចំណេះដឹង និងជំនាញដ៏សមស្របទៅនឹងការងាររបស់ខ្លួន ខណៈពេលដែលអាជីវកម្មកំពុងរីកចម្រើន ចំនួនបុគ្គលិកក៏មានកំណើនផងដែរ ដោយបានកើនពី ៧៧៦នាក់នៅឆ្នាំ២០១០ ដល់១៩១១ នៅឆ្នាំ ២០១៤ ដែលបានធ្វើឱ្យហត្ថាកសិករ ក្លាយជាស្ថាប័នមួយសំរាប់ជម្រើសការងារដ៏ល្អប្រសើរ។ សូមមើលតារាងខាងក្រោមនេះ ដែលស្ដីពីនិន្នាការនៃកំណើនបុគ្គលិកពីមួយឆ្នាំទៅមួយឆ្នាំ។



## ការចាកចេញរបស់បុគ្គលិក

បុគ្គលិកបានលាឈប់បំរើការងារជាមួយហត្ថាកសិករ នៅក្នុងឆ្នាំ២០១៤ មានចំនួន ៩.២៦% នៃបុគ្គលិកទាំងអស់ និងត្រូវបានបញ្ឈប់ពីការងារមានចំនួន ១.១៥%។ ការគណនារបស់យើង គឺបានរួមបញ្ចូលបុគ្គលិកទាំងអស់ដែលកំពុងបំរើការក្នុងពេលសាកល្បងផងដែរ។



# ការគ្រប់គ្រងសង្គម និងបរិស្ថាន



## ការធ្វើអោយហានិភ័យលើបរិស្ថាន និងសង្គមកាន់តែថយចុះ

ការគ្រប់គ្រងសង្គម និងបរិស្ថាន បានក្លាយជាដំណើរការដ៏សំខាន់មួយ ក្នុងការបកស្រាយបេសកកម្ម និងចក្ខុវិស័យរបស់យើងទៅនឹងការអនុវត្តជាក់ស្តែង។ បេសកកម្មរបស់ហត្ថាកសិករ បានបង្ហាញគ្រប់ទិដ្ឋភាពទាំងអស់នៃសកម្មភាពក្នុងសង្គមដែលរួមមាន តំបន់ភូមិសាស្ត្រនៃសេវាកម្ម (ទូទាំងប្រទេស) អតិថិជនគោលដៅ (ជាពិសេសផ្តល់ជូនអតិថិជនជាស្ត្រី និង គ្រួសារដែលមានប្រាក់ចំណូលទាបនៅតាមជនបទ) ប្រភេទនៃសេវាកម្ម (សេវាឥណទាន សេវាប្រាក់សន្សំ និងសេវាហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត) និងការពិចារណាចំពោះទំនួលខុសត្រូវផ្នែកសង្គម (និរន្តរភាពយូរអង្វែងផ្នែកហិរញ្ញវត្ថុ និងសង្គម)។ តាមរយៈការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន និងសង្គម (E&S) របស់ហត្ថាកសិករ ក្នុងឆ្នាំ២០១៤ បានបង្ហាញថា ៣០%នៃអតិថិជនសកម្ម គឺជាអតិថិជន E&S (69% ជាស្ត្រី) ដែលពួកគេត្រូវបានវាយតម្លៃលើផលប៉ះពាល់អាជីវកម្ម។ ជាលទ្ធផលហានិភ័យលើបរិស្ថាន ការបំពុលក្នុងខ្យល់បានធ្លាក់ចុះ៤% និងហានិភ័យលើសុខភាព និងរបួសរាងកាយបានថយចុះ៥% និងហានិភ័យការងារ និងលក្ខខណ្ឌការងារមិនល្អបានថយចុះ៥% ក្នុងឆ្នាំ២០១៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣។ ក្នុងទិដ្ឋភាពរួម កម្រិតមធ្យម និងខ្ពស់នៃហានិភ័យ E&S បានធ្លាក់ចុះ ៨% និង២%រៀងគ្នា ក្នុងឆ្នាំ២០១៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣ ដែលបានបង្ហាញថាអាជីវកម្មរបស់អតិថិជនហត្ថាកសិករ មានផលប៉ះពាល់លើបរិស្ថាន និងសង្គមតិចតួចជាងឆ្នាំមុន។



## ការសិក្សាលើសកម្មភាពបរិស្ថាន

តាមការសិក្សាលើការប្រើប្រាស់សម្ភារៈ ថាមពល និងទឹកប្រចាំខែរបស់ហត្ថាកសិករបានបង្ហាញថា សកម្មភាពចំពោះបរិស្ថានសម្រាប់ហត្ថាកសិករត្រូវបានគ្រប់គ្រងបានយ៉ាងល្អ និងមានភាពល្អប្រសើរ ដោយការប្រើប្រាស់មានភាពតិចតួចបំផុតដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម




## ការរីកចម្រើនចាកចេញពីភាពក្រីក្រ

ឧបករណ៍វាស់វែងសន្ទស្សន៍នៃការរីកចម្រើនចេញពីភាពក្រីក្រ (PPI) ត្រូវបានជ្រើសរើសដើម្បីវាស់វែងការរីកចម្រើនរបស់អតិថិជនហត្ថាកសិករចេញពីបន្ទាត់ភាពក្រីក្រចាប់តាំងពីឆ្នាំ២០១២មក បានឆ្លុះបញ្ចាំងពីទស្សនៈវិស័យរបស់ខ្លួនក្នុងការជួយដល់អតិថិជនអោយទទួលបានជោគជ័យក្នុងអាជីវកម្មរបស់ពួកគេ ក៏ដូចជាកែលម្អកម្រិតជីវភាពរស់នៅរបស់ពួកគេផងដែរ។ មូលដ្ឋាននៃ PPI ដែលបានស្ទាប់ស្ទង់លើអតិថិជនជាង ៧៥,២៦៤ នាក់ បានបង្ហាញថានៅដើមឆ្នាំ២០១៤ មាន២៩,៤៨% នៃអតិថិជនរបស់ហត្ថាកសិករបានរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដែលអាចរកចំណូលបានក្រោម ២.៥០ដុល្លារក្នុង១ថ្ងៃ គឺទាបជាងឆ្នាំមុន២%។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអោយឃើញពីការរីកចម្រើននៃកម្រិតជីវភាពរបស់អតិថិជនហត្ថាកសិករ ហើយសមស្របជាមួយការតាំងចិត្តរបស់ហត្ថាកសិករដែលកំណត់ថា “យើងរីកចម្រើនជាមួយនឹងអតិថិជនរបស់យើង»។

## ការការពារអតិថិជន

ហត្ថាកសិករ បានសហការជាមួយភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង ( AFD ) ដែលស្ថិតក្រោមគម្រោងរបស់ CMA ក្នុងគោលបំណងអនុវត្តផែនការសកម្មភាពឆ្ពោះទៅរកការលើកកម្ពស់គោលការណ៍ការពារអតិថិជន តាមរយៈកម្មវិធីវិញ្ញាបនប័ត្រដែលមានឈ្មោះថា «យុទ្ធនាការឆ្លាតវៃ» ( Smart Campaign ) ។ នៅចុងបញ្ចប់នៃគម្រោងនៅឆ្នាំ២០១៥នេះ ហត្ថាកសិករ បានខិតខំប្រឹងប្រែងដើម្បីបានការបញ្ជាក់លើគោលការណ៍ការពារអតិថិជនដោយយុទ្ធនាការឆ្លាតវៃនេះ បន្ទាប់ពីបានពិនិត្យចំនុចមួយចំនួនដូចខាងក្រោមនេះ៖

- ផលិតផលត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជនយ៉ាងទូលំទូលាយ។ហត្ថាកសិករផ្តល់តម្លៃចំពោះមតិយោបល់របស់អតិថិជន និងរិះរកវិធីដោះស្រាយទៅតាមកម្រិតនៃបញ្ហា និងបង្កើនទំនាក់ទំនងជាមួយពួកគេ។
- ហត្ថាកសិករ បង្ហាញការអនុវត្តយ៉ាងខ្លាំងក្លាលើគោលការណ៍ការពារការជំពាក់បំណុលវ័ណ្ឌក ជាមួយនឹងការយល់ដឹងក្នុងកម្រិតខ្ពស់លើហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក ជាពិសេសនៅក្នុងបរិបទរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន។
- ការកំណត់តម្លៃស្របតាមលក្ខណៈវិនិច្ឆ័យបច្ចេកទេសដែលអាចធានាបាននូវការចំណាយក្នុងការផ្តល់ប្រាក់កម្ចីត្រូវបានគ្របដណ្តប់យ៉ាងពេញលេញ ។
- ហត្ថាកសិករ មានតម្លាភាពពេញលេញក្នុងការកំណត់តម្លៃ រយៈពេល និងលក្ខខណ្ឌផលិតផល ហិរញ្ញវត្ថុទាំងអស់
- ហត្ថាកសិករ បង្ហាញពីការអនុវត្តន៍ដ៏ល្អចំពោះអតិថិជនដោយស្មើភាព និងដោយក្តីគោរព។ ហត្ថាកសិករ ប្រើប្រាស់ការអនុវត្តន៍ដោយការគោរព និងប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌ខ្ពស់ក្នុងការដោះស្រាយជាមួយអតិថិជន។
- ហត្ថាកសិករ ធានាឯកជនភាពនៃព័ត៌មានអតិថិជនតនិងការពារអតិថិជន អាជីវកម្ម និងឧស្សាហកម្មទាំងមូល។
- ហត្ថាកសិករ ផ្តល់នូវវិធីសាស្ត្រច្រើនយ៉ាងសម្រាប់អតិថិជនអាចដាក់បណ្តឹងតវ៉ារបស់ពួកគេ ដើម្បីអោយការបំរើសេវាកម្មកាន់តែមានប្រសិទ្ធិភាពខ្ពស់។

ជាមួយនឹងគោលដៅសង្គម និងការតាំងចិត្តចំពោះសកម្មភាពសង្គម ហត្ថាកសិករ បានទទួលចំណាត់ថ្នាក់ពី Planet Rating Agency ដែលមានចំណាត់ថ្នាក់លេខ “៤- “ ដែលត្រូវគ្នាទៅនឹងកម្រិត “ភាពជឿជាក់” ពោលគឺបានផ្លាស់ប្តូរពីកម្រិត«ល្អ»ទៅម្រិត «ល្អបំផុត» ។ ចំណាត់ថ្នាក់នេះ មានន័យថាហត្ថាកសិករ មានការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ទៅនឹងគោលដៅសង្គម ការគ្រប់គ្រងសមហេតុផលនៃសកម្មភាពសង្គម និងការទទួលខុសត្រូវហានិភ័យសង្គម ព្រមទាំងជាស្ថាប័នដែលទទួលបានផលប៉ះពាល់សង្គមជាវិជ្ជមានផងដែរ។



# ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

ដំណើរការនៃការគ្រប់គ្រងហានិភ័យ ត្រូវបានចាត់ទុកថាមានសារៈសំខាន់សម្រាប់កំណើនអាជីវកម្មប្រកបដោយគុណភាព និងបានរចនាឡើងដើម្បីប្រមើលមើលពីហានិភ័យនៃហេតុការណ៍ដែលកំពុងកើតមានឡើង ហើយអាចជះផលអវិជ្ជមានលើដំណើរការអាជីវកម្មរបស់ស្ថាប័ន។ ដើម្បីអោយការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងបង្កើតវប្បធម៌នៃហានិភ័យ និងប្រតិបត្តិតាមដ៏រឹងមាំមួយ ហត្ថាកសិករ លីមីតធីត បានដាក់ដំណើរការក្របខ័ណ្ឌហានិភ័យ និងប្រតិបត្តិតាម សម្រាប់ការអនុវត្ត និងគ្រប់គ្រងហានិភ័យ ដែលរួមមានគោលនយោបាយ នីតិវិធី ឧបករណ៍ និងមុខងារតួនាទីច្បាស់លាស់ និងទំនួលខុសត្រូវរបស់នយោជិត។




### តួនាទីរបស់គណៈកម្មការគ្រប់គ្រងទ្រព្យ ហានិភ័យ និងបំណុលរួមមាន:

- គ្រប់គ្រងរាល់ហានិភ័យលើប្រតិបត្តិការទ្រព្យនិងបំណុលនិងរៀបចំយុទ្ធសាស្រ្តដើម្បីគ្រប់គ្រង និងការវាស់វែងហានិភ័យ។
- ត្រួតពិនិត្យជាប្រចាំលើគោលនយោបាយ ដែលបន្តនូវការបង្ហាញពីលក្ខណៈនៃហានិភ័យដែលកើតឡើងនៅក្នុងហត្ថាកសិករ ដើម្បីផ្តល់អនុសាសន៍ផ្លាស់ប្តូរទៅកាន់ ARBC និងក្រុមប្រឹក្សាភិបាល។
- គ្រប់គ្រងរាល់ហានិភ័យស្របទៅនឹងច្បាប់ និងគោលនយោបាយដែលបានអនុវត្តសម្រាប់ហត្ថាកសិករ ដែលស្ថិតនៅក្រោមច្បាប់របស់ប្រទេសកម្ពុជា និងក្រោមការកំណត់ ដែលជាគោលការណ៍បង្កើតឡើងដោយ ក្រុមប្រឹក្សាភិបាល និង ARBC ។
- ត្រួតពិនិត្យជាប្រចាំលើគោលនយោបាយ ដែលបន្តនូវការបង្ហាញពីលក្ខណៈនៃហានិភ័យដែលកើតឡើងនៅក្នុងហត្ថាកសិករ ដើម្បីផ្តល់អនុសាសន៍ផ្លាស់ប្តូរទៅកាន់ ARBC និងក្រុមប្រឹក្សាភិបាល ។

ក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តយ៉ាងពេញលេញនៅការិយាល័យកណ្តាល និងតាមបណ្តាសាខា។ មុខងារ និងតួនាទីសំខាន់របស់នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម គឺអនុវត្តក្របខ័ណ្ឌនេះ រួមមានការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យឥណទាន និងកម្មវិធីហានិភ័យប្រតិបត្តិតាម។ ជាលទ្ធផល យើងបានសម្រេចផែនការនេះដោយបានធ្វើការវាយតម្លៃលើហានិភ័យសំខាន់ៗ និងកត់ត្រាទុកក្នុងបញ្ជីហានិភ័យ ហើយធ្វើការតាមដានជាប្រចាំ និងសម្របសម្រួលជាមួយនឹងរបាយការណ៍ស្វ័យវាយតម្លៃហានិភ័យ និងត្រួតពិនិត្យ (RCSA) ព្រមទាំងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកគ្រប់សាខាទាំងអស់នៅលើទស្សនៈពីហានិភ័យ និងការគ្រប់គ្រងហានិភ័យ។

# របាយការណ៍ សវនករឯករាជ្យ

## ជូនចំពោះភាគទុនិក ហត្ថាកសិករ លីមីតធីត

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ហត្ថាកសិករ លីមីតធីត ហៅកាត់ថា (“ក្រុមហ៊ុន” ឬ ”អេច ខេ អិល”) ដែលរួមមានតារាងតុល្យការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងរបាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់កាលបរិច្ឆេទដែលបាន បញ្ចប់ និងកំណត់សម្គាល់ដែលរួមមានសេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ នេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃ កម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងទទួលខុសត្រូវលើ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺការបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយផ្អែកទៅលើការធ្វើ សវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ស្តង់ដារទាំងនោះ តម្រូវឲ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការនៃក្រមសីលធម៌ និងគ្រោង និងធ្វើសវនកម្ម ដើម្បី ទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុ ពុំមានការបង្ហាញខុសជាសារវន្ត ឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានីតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទង ទៅនឹងចំនួនទឹកប្រាក់ និងការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធី ទាំងនេះ គឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យដែលមាន ផលប៉ះពាល់ដល់ការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ បណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីធ្វើ សវនកម្មឲ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិទៅ លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។ ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅ លើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើងដោយអ្នកគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញ នៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិសវនកម្ម

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់ ហត្ថាកសិករ លីមីតធីត នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យ កម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់




រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥

# របាយការណ៍ហិរញ្ញវត្ថុ

## តារាងតុល្យការ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ២០១៤ | | ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល | ដុល្លារអាមេរិក | រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៧,១៣៩,៨១៨ | ២៩,០៩៤,៧៥៨ | ៥,២០១,១៦២ | ២០,៧៧៨,៦៤២ |
| សមតុល្យនៅធនាគារកណ្តាល | ២៥,៩២២,៣៦៦ | ១០៥,៦៣៣,៦៤២ | ៧,៨៨០,៦១៤ | ៣១,៤៨៣,០៥៣ |
| សមតុល្យនៅធនាគារ | ២៣,២០៤,០០២ | ៩៤,៥៥៦,៣០៨ | ១៤,២២១,៩៣០ | ៥៦,៨១៦,៦១០ |
| សម្ភាធឥណទាន | ២៤៩,៦៨០,២៥២ | ១,០១៧,៤៤៧,០២៧ | ១៤៤,១៩៤,៥៧០ | ៥៧៦,០៥៧,៣០៧ |
| ទ្រព្យសកម្មផ្សេងៗ | ៤,៨៦០,៣៩០ | ១៩,៨០៦,០៨៩ | ៣,២២៦,៦៤៧ | ១២,៨៩០,៤៥៥ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៤,៣១១,០២៤ | ១៧,៥៦៧,៤២៣ | ៣,២៧៣,២៧៧ | ១៣,០៧៦,៧៤២ |
| ទ្រព្យសកម្មអរូបិយ | ១,១៦៣,៣១១ | ៤,៧៤០,៤៩២ | ១,៥៧៤,៤៨៦ | ៦,២៩០,០៧២ |
| ពន្ធពន្យារទ្រព្យសកម្ម | ៨២,៦៤២ | ៣៣៦,៧៦៦ | - | - |
| **ទ្រព្យសកម្មសរុប** | **៣១៦,៣៦៣,៨០៥** | **១,២៨៩,១៩២,៥០៥** | **១៧៩,៥៧២,៦៨៦** | **៧១៧,៣៩២,៨៨១** |
| **ទ្រព្យអកម្ម និងមូលធនភាគទុនិក** | | | | |
| **ទ្រព្យអកម្ម** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៧២,៣៣៣,៣៥២ | ៧០២,២៥៨,៤០៩ | ៨២,៤៧៣,៥៧៥ | ៣២៩,៤៨១,៩៣២ |
| ចំនួនកម្ចី | ៥៧,៧០២,១៤៩ | ២៣៥,១៣៦,២៥៧ | ៤៧,២៦៦,៣៣០ | ១៨៨,៨២៨,៩៨៨ |
| ទឹកប្រាក់ជំពាក់ភាគទុនិក | ២២,៩៧០,៨២១ | ៩៣,៦០៦,០៨៦ | ១៣,៣៩៣,៦១៧ | ៥៣,៥០៧,៥០០ |
| អនុបំណុល | ១៤,៩៤២,៧៧៨ | ៦០,៨៩១,៨២០ | ៦,០០០,០០០ | ២៣,៩៧០,០០០ |
| អត្ថប្រយោជន៍សោធននិវត្តន៍ | ១,២៨៥,២០៨ | ៥,២៣៧,២២៣ | ៩១២,៥១៨ | ៣,៦៤៥,៥១០ |
| ទ្រព្យអកម្មផ្សេងៗ | ៦,៦២៤,៥៥៣ | ២៦,៩៩៥,០៥៣ | ៣,៣៩២,៧៨៩ | ១៣,៥៥៤,១៩២ |
| ពន្ធពន្យារទ្រព្យអកម្ម | - | - | ២៨,២៩៧ | ១១៣,០៤៧ |
| សំវិធានធនលើប្រាក់ចំណេញ | ១,៧៦០,២២៩ | ៧,១៧២,៩៣៣ | ៨៤២,១៨២ | ៣,៣៦៤,៥១៧ |
| **ទ្រព្យអកម្មសរុប** | **២៧៧,៦១៩,០៩០** | **១,១៣១,២៩៧,៧៩១** | **១៥៤,៣០៩,៣០៨** | **៦១៦,៤៦៥,៦៨៦** |
| **មូលធនភាគទុនិក** | | | | |
| ដើមទុនភាគហ៊ុន | ៥,២៧១,១៨៨ | ២១,៤៨០,០៩១ | ៤,០៣៦,៨០០ | ១៦,១២៧,០១៦ |
| បុព្វលាភភាគហ៊ុន | ១០,៤៩២,៧១៧ | ៤២,៧៥៧,៨២២ | ៥,៥១៥,៧០៤ | ២២,០៣៥,២៣៣ |
| ទុនបម្រុង | ៥២៧,១១៩ | ២,១៤៨,០១០ | ៤០៣,៦៨០ | ១,៦១២,៧០២ |
| ទុនបម្រុងផ្សេងៗ | ៦៣៥,៣៨២ | ២,៥៨៩,១៨២ | ៤៦៥,២៧២ | ១,៨៥៨,៧៦២ |
| អនុបំណុល | ៧២៩,៣១៩ | ២,៩៧១,៩៧៥ | ៧២៩,៣១៩ | ២,៩១៣,៦២៩ |
| ប្រាក់ចំណេញរក្សាទុក | ២១,០៨៨,៩៩០ | ៨៥,៩៣៧,៦៣៤ | ១៤,១១២,៦០៣ | ៥៦,៣៧៩,៨៤៩ |
| **មូលធនភាគទុនិកសរុប** | **៣៨,៧៤៤,៧១៥** | **១៥៧,៨៩៤,៧១៤** | **២៥,២៦៣,៣៧៨** | **១០០,៩២៧,១៩៥** |
| **ទ្រព្យអកម្ម និងមូលធនភាគទុនិកសរុប** | **៣១៦,៣៦៣,៨០៥** | **១,២៨៩,១៩២,៥០៥** | **១៧៩,៥៧២,៦៨៦** | **៧១៧,៣៩២,៨៨១** |

# របាយការណ៍ប្រាក់ចំណេញ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ២០១៤ | | ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល | ដុល្លារអាមេរិក | រៀល |
| ចំណូលការប្រាក់ | ៤៥,៤៩៦,៨០១ | ១៨៥,៣៩៩,៤៦៤ | ៣០,០៣៥,២៣៩ | ១១៩,៩៩០,៧៨០ |
| ចំណាយការប្រាក់ | ( ១៦,៨៨១,២៨៦ ) | ( ៦៨,៧៩១,២៤០ ) | ( ៩,៥៥៦,៣០៥ ) | ( ៣៨,១៧៧,៤៣៨ ) |
| **ចំណូលការប្រាក់សុទ្ធ** | **២៨,៦១៥,៥១៥** | **១១៦,៦០៨,២២៤** | **២០,៤៧៨,៩៣៤** | **៨១,៨១៣,៣៤២** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ២៨២,២១៨ | ១,១៥០,០៣៨ | ៤៨០,៩១៦ | ១,៩២១,២៥៩ |
| **ចំណូលប្រតិបត្តិការ** | **២៨,៨៩៧,៧៣៣** | **១១៧,៧៥៨,២៦២** | **២០,៩៥៩,៨៥០** | **៨៣,៧៣៤,៦០១** |
| ចំណាយទូទៅ និងរដ្ឋបាល | ( ១៩,៦០៩,៣៦២ ) | ( ៧៩,៩០៨,១៥០ ) | ( ១៥,០៩៣,០៣១ ) | ( ៦០,២៩៦,៦៥៩ ) |
| សំវិធានធនត្រឡប់/ សំវិធានធនទៅលើ ឥណទានខូច និងសង្ស័យ | ៩១១,៨៩៧ | ៣,៧១៥,៩៨០ | ( ៥១០,៩២៨ ) | ( ២,០៤១,១៥៧ ) |
| **ប្រាក់ចំណេញមុនពេលបង់ពន្ធ** | **១០,២០០,២៦៨** | **៤១,៥៦៦,០៩២** | **៥,៣៥៥,៨៩១** | **២១,៣៩៦,៧៨៥** |
| ចំណាយពន្ធលើប្រាក់ចំនេញ | ( ២,០៧៨,៣៣៣ ) | ( ៨,៤៦៩,២០៧ ) | ( ១,០៩៥,៨៩៦ ) | ( ៤,៣៧៨,១០៥ ) |
| **សាច់ប្រាក់សុទ្ធចំនេញប្រចាំឆ្នាំ** | **៨,១២១,៩៣៥** | **៣៣,០៩៦,៨៨៥** | **៤,២៥៩,៩៩៥** | **១៧,០១៨,៦៨០** |

# របាយការណ៍បំរែបំរួលភាគទុនិកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ដើមទុន<br>ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន<br>ដុល្លារអាមេរិក | ទុនបំរុង<br>ដុល្លារអាមេរិក | ទុនបំរុងផ្សេងៗ<br>ដុល្លារអាមេរិក | អនុបំណុល<br>ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ | ៤,០៣៦,៨០០ | ៥,៥១៥,៧០៤ | ៤០៣,៦៨០ | ២៩៥,១៦២ | ៧២៩,៣១៩ | ១០,៩០៦,៣៩៣ | ២១,៨៨៧,០៥៨ |
| ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ | - | - | - | - | - | ៤,២៥៩,៩៩៥ | ៤,២៥៩,៩៩៥ |
| ការផ្ទេរទៅទុនបម្រុង | - | - | - | ១៧០,១១០ | - | ( ១៧០,១១០ ) | - |
| ការបែងចែកភាគលាភ | - | - | - | - | - | ( ៨៨៣,៦៧៥ ) | ( ៨៨៣,៦៧៥ ) |
| **ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៣** | **៤,០៣៦,៨០០** | **៥,៥១៥,៧០៤** | **៤០៣,៦៨០** | **៤៦៥,២៧២** | **៧២៩,៣១៩** | **១៤,១១២,៦០៣** | **២៥,២៦៣,៣៧៨** |
| (KHR'000 equivalents) | | | | | | | |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | **១៦,៤៤៩,៩៦០** | **២២,៤៧៦,៤៩៤** | **១,៦៤៤,៩៩៦** | **១,៨៩៥,៩៨៣** | **២,៩៧១,៩៧៥** | **៥៧,៥០៨,៨៥៧** | **១០២,៩៤៨,២៦៥** |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ៤,០៣៦,៨០០ | ៥,៥១៥,៧០៤ | ៤០៣,៦៨០ | ៤៦៥,២៧២ | ៧២៩,៣១៩ | ១៤,១១២,៦០៣ | ២៥,២៦៣,៣៧៨ |
| ដើមទុនបន្ថែម | ១,២៣៤,៣៨៨ | ៤,៩៧៧,០១៣ | - | - | - | - | ៦,២១១,៤០១ |
| ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ | - | - | - | - | - | ៨,១២១,៩៣៥ | ៨,១២១,៩៣៥ |
| ការផ្ទេរទៅទុនបម្រុង | - | - | ១២៣,៤៣៩ | - | - | ( ១២៣,៤៣៩ ) | - |
| ការផ្ទេរទៅទុនបម្រុងផ្សេងៗ | - | - | - | ១៧០,១១០ | - | ( ១៧០,១១០ ) | - |
| ការបែងចែកភាគលាភ | - | - | - | - | - | ( ៨៥១,៩៩៩ ) | ( ៨៥១,៩៩៩ ) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៥,២៧១,១៨៨** | **១០,៤៩២,៧១៧** | **៥២៧,១១៩** | **៦៣៥,៣៨២** | **៧២៩,៣១៩** | **២១,០៨៨,៩៩០** | **៣៨,៧៤៤,៧១៥** |
| (KHR'000 equivalents) | | | | | | | |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **២១,៤៨០,០៩១** | **៤២,៧៥៧,៨២២** | **២,១៤៨,០១០** | **២,៥៨៩,១៨២** | **២,៩៧១,៩៧៥** | **៨៥,៩៣៧,៦៣៤** | **១៥៧,៨៨៤,៧១៤** |

# របាយការណ៍លំហូរសាច់ប្រាក់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ២០១៤ | | ២០១៣ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **រៀល** | **ដុល្លារអាមេរិក** | **រៀល** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| លំហូរសាច់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ | (១០,៣៥៥,៥៣៨) | (៤២,១៩៨,៨១៧) | (១,២៤០,៦៧៩) | (៤,៩៥៦,៥១២) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (២,៥២៤,១១៨) | (១០,២៨៥,៧៨១) | (១,៩៤០,៨៤០) | (៧,៧៥៣,៦៥៦) |
| ការទិញទ្រព្យសកម្មអរូបិយ | (៤៧,៥៥៩) | (១៩៣,៨០៣) | (៨៣,៥០៤) | (៣៣៣,៥៩៨) |
| សាច់ប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២២,៤៦៥ | ៤៩៩,០៤៥ | ២០៧ | ៨២៧ |
| សាច់ប្រាក់សុទ្ធបានមកពីការវិនិយោគ | (២,៤៤៩,២១២) | (៩,៩៨០,៥៣៩) | (២,០២៤,១៣៧) | (៨,០៨៦,៤២៧) |
| **លំហូរសាច់ប្រាក់បានមកពីហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | ២៧,០៩០,៣៨៥ | ១១០,៣៩៣,៣១៩ | ១៣,៣៨២,៧២៨ | ៥៣,៤៦៣,៩៩៨ |
| ការសងប្រាក់កម្ចី | (១៦,៦៥៤,៥៦៦) | (៦៧,៨៦៧,៣៥៦) | (៦,១៨១,៤០៩) | (២៤,៦៩៤,៧២៩) |
| សាច់ប្រាក់បានមកពីមូលធនភាគទុនិក | ១២,៩៦៤,៦៨៦ | ៥២,៨៣១,០៩៥ | ១០,៥៣៩,៤២៤ | ៤២,១០៤,៩៩៩ |
| ការសងប្រាក់ឲ្យទៅភាគទុនិក | (៣,៣៨៧,៤៨២) | (១៣,៨០៣,៩៨៩) | (៧,៦១៨,៤៧៣) | (៣០,៤៣៥,៨០០) |
| សាច់ប្រាក់សុទ្ធបានមកពីអនុបំណុល | ១០,០០០,០០០ | ៤០,៧៥០,០០០ | ៤,០០០,០០០ | ១៥,៩៨០,០០០ |
| សាច់ប្រាក់សុទ្ធបានមកពីដើមទុនបន្ថែម | ៥,១៥៤,១៧៩ | ២១,០០៣,២៧៩ | - | - |
| ភាគលាភបានបង់ | (៨៥១,៩៩៩) | (៣,៤៧១,៨៩៦) | (៨៨៣,៦៧៥) | (៣,៥៣០,២៨២) |
| សាច់ប្រាក់សុទ្ធបានមកពីហិរញ្ញប្បទាន | ៣៤,៣១៥,២០៣ | ១៣៩,៨៣៤,៤៥២ | ១៣,២៣៨,៥៩៥ | ៥២,៨៨៨,១៨៦ |
| **ការកើនឡើងនៃសាច់ប្រាក់សុទ្ធ និងសាច់ប្រាក់សមមូល** | ២១,៥១០,៤៥៣ | ៨៧,៦៥៥,០៩៦ | ៩,៩៧៣,៧៧៩ | ៣៩,៨៤៥,២៤៧ |
| **សាច់ប្រាក់និងសាច់ប្រាក់នាដើមឆ្នាំ** | ១៩,៩៥៦,៥៥៥ | ៨១,៣២២,៩៦១ | ៩,៩៨២,៧៧៦ | ៣៩,៨៨១,១៩០ |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៤១,៤៦៧,០០៨ | ១៦៨,៩៧៨,០៥៧ | ១៩,៩៥៦,៥៥៥ | ៧៩,៧២៦,៤៣៧ |

# ពានរង្វាន់ ចំណាត់ថ្នាក់ ដៃគូវិនិយោគ

## ពានរង្វាន់ & ចំណាត់ថ្នាក់




## ភាគទុនិក របស់ហត្ថាកសិករ

OIKO CREDIT investing in people

responsAbility

Triple Jump

Hattha Kaksekar NGO

Norfund

Dr. DY DAVUTH

responsAbility Participations

A., Limited

## ដៃគូវិនិយោគ របស់ហត្ថាកសិករ

## ហត្ថាកសិករ ជាសមាជិក

# តំបន់ប្រតិបត្តិការ និងបណ្តាញសាខា




## បណ្តាញការិយាល័យសាខា

ខេត្ត/ក្រុង : ២៥ , ការិយាល័យកណ្តាល : ១ , សាខា : ៤៩ , សាខារង : ៨១ , ប៉ុស្តិ៍សេវា : ១១ , អេធីអឹម : ៧២

# អាសយដ្ឋានការិយាល័យ ហត្ថាកសិករ

## ០១ ការិយាល័យកណ្តាល

អគារលេខ៦០៦ ផ្លូវលេខ២៧១ ភូមិ៦ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រ: ២០៤៤ ភ្នំពេញ៣
ទូរស័ព្ទ: 023 994 304 / 023 224 102
អ៊ីម៉េល: info@hkl.com.kh
គេហទំព័រ: www.hkl.com.kh

## ០២ ការិយាល័យប្រតិបត្តិការ

អគារលេខ៦០៦ ផ្លូវលេខ២៧១ ភូមិ៦ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: 023 994 304 / 069 666 264
អ៊ីម៉េល: bm.hoo@hkl.com.kh

## ០៣ សាខាដង្កោ, ភ្នំពេញ

ផ្លូវសហព័ន្ធរុស្ស៊ី  ភូមិប៉ប្រកជើង សង្កាត់កាកាប
ខណ្ឌពោធិ៍សែនជ័យ  រាជធានីភ្នំពេញ
ទូរស័ព្ទ: 069 666 247
អ៊ីម៉េល: bm.dnk@hkl.com.kh

## ០៤ សាខាដូនពេញ, ភ្នំពេញ

អគារលេខ៩២B-៩២C  ផ្លូវលេខ៧០  ក្រុម៤  ភូមិ១ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ: 069 666 238
អ៊ីម៉េល: bm.dnp@hkl.com.kh

## ០៥ សាខារាជធានីភ្នំពេញ, ភ្នំពេញ

អគារលេខ៦០៦ ផ្លូវលេខ២៧១ ភូមិ៦ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: 069 666 174
អ៊ីម៉េល: bmb7@hkl.com.kh

## ០៦ សាខាឬស្សីកែវ, ភ្នំពេញ

អគារលេខ១៩០ ផ្លូវជាតិលេខ៥ ក្រុម១ ភូមិ២ សង្កាត់ច្រាំងចំរេះទី១
ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ: 069 666 124
អ៊ីម៉េល: bm.rsk@hkl.com.kh

## ០៧ សាខាបឹងត្របែក, ភ្នំពេញ

អគារលេខ៣៩ ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន
រាជធានីភ្នំពេញ
ទូរស័ព្ទ: 069 666 053
អ៊ីម៉េល: bm.btk@hkl.co.kh

## ០៨ សាខាបាត់ដំបង, បាត់ដំបង

អគារលេខ១៨ ១៩ ២០ ក្រុមទី៤ ភូមិព្រែកមហាទេព
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទ: 069 666 254
អ៊ីម៉េល: bmb9@hkl.com.kh

## ០៩ សាខាបវេល, បាត់ដំបង

ភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង
ទូរស័ព្ទ: 069 666 251
អ៊ីម៉េល: bm.bvl@hkl.com.kh

## ១០ សាខាពោធិ៍សាត់, ពោធិ៍សាត់

ផ្លូវជាតិលេខ៥  ភូមិស្ថានីយ៍ សង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់
ខេត្តពោធិ៍សាត់
ទូរស័ព្ទ: 069 666 130
អ៊ីម៉េល: bmb1@hkl.com.kh

## ១១ សាខាបាកាន, ពោធិ៍សាត់

ផ្លូវជាតិលេខ៥ ភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន
ខេត្តពោធិ៍សាត់
ទូរស័ព្ទ:  069 666 261
អ៊ីម៉េល: bm.bkn@hkl.com.kh

## ១២ សាខាកំពង់ចាម, កំពង់ចាម

ផ្លូវជាតិលេខ៧ថ្មី ក្រុមទី៣ ភូមិបឹងស្នាយ សង្កាត់សំបួរមាស
ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ទូរស័ព្ទ: 069 666 237
អ៊ីម៉េល: bmb8@hkl.com.kh

### ១៣ សាខាព្រៃឈរ, កំពង់ចាម

ផ្លូវជាតិលេខ៧ ភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរខេត្តកំពង់ចាម
ទូរសព្ទ: 069 666 152
អ៊ីម៉ែល: bm.pch@hkl.com.kh

### ១៤ សាខាត្បូងឃ្មុំ, កំពង់ចាម

ភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ
ទូរសព្ទ: 069 666 093
អ៊ីម៉ែល: bm.tkm@hkl.com.kh

### ១៥ សាខាមេមត់, កំពង់ចាម

ផ្លូវជាតិលេខ៧ ភូមិត្បូងវត្ត ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
ទូរសព្ទ: 069 666 204
អ៊ីម៉ែល: bm.mmt@hkl.com.kh

### ១៦ សាខាពញាក្រែក, កំពង់ចាម

ផ្លូវជាតិលេខ៧ ភូមិកណ្ដាលកោង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ
ទូរសព្ទ: 069 666 051
អ៊ីម៉ែល: bm.pnk@hkl.com.kh

### ១៧ សាខាស្ទឹងសែន, កំពង់ធំ

អគារលេខ៦ ផ្លូវជាតិលេខ៦ ភូមិដំរីជាន់ខ្លា សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ទូរសព្ទ: 069 666 105
អ៊ីម៉ែល: bmb5@hkl.com.kh

### ១៨ សាខាបារាយណ៍, កំពង់ធំ

ផ្លូវជាតិលេខ៦ ភូមិកំពង់ថ្ម ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ
ទូរសព្ទ: 069 666 257
អ៊ីម៉ែល: bm.barray@hkl.com.kh

### ១៩ សាខាស្ទោង, កំពង់ធំ

ភូមិឈើទាល ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ
ទូរសព្ទ: 069 666 107
អ៊ីម៉ែល: bmb2@hkl.com.kh

### ២០ សាខាសៀមរាប, សៀមរាប

ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
ទូរសព្ទ: 069 666 120
អ៊ីម៉ែល: bmb4@hkl.com.kh

### ២១ សាខាជីក្រែង, សៀមរាប

ភូមិកំពង់ក្ដី២ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប
ទូរសព្ទ: 069 666 248
អ៊ីម៉ែល: bm.ckg@hkl.com.kh

### ២២ សាខាសូទ្រនិគម, សៀមរាប

ផ្លូវជាតិលេខ៦ ក្រុមទី១ ភូមិដំដែកថ្មី ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប
ទូរសព្ទ: 069 666 110
អ៊ីម៉ែល: bm.snk@hkl.com.kh

### ២៣ សាខាពួក, សៀមរាប

ផ្លូវជាតិលេខ៦ ភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប
ទូរសព្ទ : 069 666 157
អ៊ីម៉ែល: bm.puk@hkl.com.kh

### ២៤ សាខាក្រុងសៀមរាប, សៀមរាប

អគារលេខ០១៧៩ ក្រុមទី៣ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរសព្ទ: 069 666 253
អ៊ីម៉ែល: KSR.BM@hkl.com.kh

### ២៥ សាខាបន្ទាយមានជ័យ, បន្ទាយមានជ័យ

អគារលេខ១៥២-១៥៣ ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរសព្ទ: 069 666 258
អ៊ីម៉ែល: bmb6@hkl.com.kh

### ២៦ សាខាប៉ោយប៉ែត, បន្ទាយមានជ័យ

អគារលេខ០៩១ ភូមិអូរជ្រៅ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរសព្ទ: 069 666 173
អ៊ីម៉ែល: bm.ppt@hkl.com.kh

## ២៧ សាខាថ្មពួក, បន្ទាយមានជ័យ

ភូមិផ្សារថ្មី ឃុំគុំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
ទូរសព្ទ: 069 666 091
អ៊ីម៉ែល: bm.tpk@hkl.com.kh

## ២៨ សាខាក្រុងតាខ្មៅ, កណ្ដាល

អគារលេខ១៦៦ ផ្លូវជាតិលេខ២ ភូមិក្រពើហា សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរសព្ទ: 069 666 094
អ៊ីម៉ែល: bm.tmo@hkl.com.kh

## ២៩ សាខាកៀនស្វាយ, កណ្ដាល

អគារលេខ៣៥០ ផ្លូវជាតិលេខ១ ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល
ទូរសព្ទ: 069 666 217
អ៊ីម៉ែល: bm.ksy@hkl.com.kh

## ៣០ សាខាមុខកំពូល, កណ្ដាល

អគារលេខ៣៦ ផ្លូវជាតិលេខ៦ ភូមិព្រែកតាបែន ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល
ទូរសព្ទ: 069 666 183
អ៊ីម៉ែល: bm.mkp@hkl.com.kh

## ៣១ សាខាអង្គស្នួល, កណ្ដាល

អគារលេខ១៧ ផ្លូវជាតិលេខ៤ ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល
ទូរសព្ទ: 069 666 067
អ៊ីម៉ែល: bm.asl@hkl.com.kh

## ៣២ សាខាស្អាង, កណ្ដាល

អគារលេខ៣១៥ ផ្លូវលេខ២១ ភូមិក្នុងព្រែក ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល
ទូរសព្ទ: 069 666 073
អ៊ីម៉ែល: bm.sag@hkl.com.kh

## ៣៣ សាខាព្រៃវែង, ព្រៃវែង

ផ្លូវជាតិលេខ១១ ភូមិលេខ៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
ទូរសព្ទ: 069 666 145
អ៊ីម៉ែល: bm.pvn@hkl.com.kh

## ៣៤ សាខាពាមរក៍, ព្រៃវែង

ភូមិ១ ឃុំព្រែកខ្សាយ ខ ស្រុកពាមរក៍ ខេត្តព្រៃវែង
ទូរសព្ទ: 069 666 175
អ៊ីម៉ែល: bm.pro@hkl.com.kh

## ៣៥ សាខាតាកែវ, តាកែវ

ផ្លូវជាតិលេខ២ ភូមិទ្បូរី សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
ទូរសព្ទ: 069 666 101
អ៊ីម៉ែល: bm.tak@hkl.com.kh

## ៣៦ សាខាព្រៃកប្បាស, តាកែវ

ភូមិព្រៃល្វាកើត ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ
ទូរសព្ទ: 069 666 150
អ៊ីម៉ែល: bm.pkb@hkl.com.kh

## ៣៧ សាខាកំពង់ឆ្នាំង, កំពង់ឆ្នាំង

ភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរសព្ទ: 069 666 232
អ៊ីម៉ែល: bmb10@hkl.com.kh

## ៣៨ សាខាកំពត, កំពត

អគារលេខ៦៤ ផ្លូវជាតិលេខ៣ ភូមិក្រាំង  សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត
ទូរសព្ទ: 069 666 219
អ៊ីម៉ែល: bm.kpt@hkl.com.kh

## ៣៩ សាខាកំពង់ស្ពឺ, កំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរសព្ទ: 069 666 230
អ៊ីម៉ែល: bm.ksp@hkl.co m.kh

## ៤០ សាខាព្រះសីហនុ, ព្រះសីហនុ

អគារលេខ៤៨០ ផ្លូវឯករាជ្យ ក្រុមទី១១ ភូមិ២ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរសព្ទ: 069 666 154
អ៊ីម៉ែល: bm.snv@hkl.com.kh

## ៤១ សាខាកោះកុង, កោះកុង

អគារលេខ៥០៤ ផ្លូវជាតិ៤៨ ក្រុមទី១៤ ភូមិទី១
សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
ទូរសព្ទ: 069 666 213
អ៊ីម៉ែល: bm.kkg@hkl.com.kh

## ៤២ សាខាស្វាយរៀង, ស្វាយរៀង

អគារលេខ១១ ផ្លូវជាតិលេខ១ ភូមិសួនថ្មី សង្កាត់ព្រៃឆ្លាក់
ក្រុងស្វាយរៀង ខេត្តស្វាយរៀង
ទូរសព្ទ: 069 666 104
អ៊ីម៉ែល: bm.svg@hkl.com.kh

## ៤៣ សាខាក្រចេះ, ក្រចេះ

ផ្លូវជាតិលេខ៧ ភូមិអូរឫស្សីទី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ
ខេត្តក្រចេះ
ទូរសព្ទ: 069 666 208
អ៊ីម៉ែល: bm.kte@hkl.com.kh

## ៤៤ សាខាស្ទឹងត្រែង, ស្ទឹងត្រែង

ផ្លូវ៧ចាស់ ភូមិភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង
ខេត្តស្ទឹងត្រែង
ទូរសព្ទ: 069 666 108
អ៊ីម៉ែល: bm.stg@hkl.com.kh

## ៤៥ សាខាមណ្ឌលគិរី, មណ្ឌលគិរី

ផ្លូវជាតិលេខ៧៦ ភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ
ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
ទូរសព្ទ: 069 666 185
អ៊ីម៉ែល: bm.mkr@hkl.com.kh

## ៤៦ សាខារតនគិរី, រតនគិរី

អគារលេខ៤៧ ភូមិទី១ សង្កាត់ឡាបានសៀក ក្រុងបានលុង
ខេត្តរតនគិរី
ទូរសព្ទ: 069 666 129
អ៊ីម៉ែល: bm.rkr@hkl.com.kh

## ៤៧ សាខាឧត្ដរមានជ័យ, ឧត្ដរមានជ័យ

ផ្លូវជាតិលេខ៦៨ ភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង
ខេត្តឧត្ដរមានជ័យ
ទូរសព្ទ: 069 666 176
អ៊ីម៉ែល: bm.omc@hkl.com.kh

## ៤៨ សាខាព្រះវិហារ, ព្រះវិហារ

ភូមិឡូតដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
ទូរសព្ទ: 069 666 153
អ៊ីម៉ែល: bm.pvh@hkl.com.kh

## ៤៩ សាខាប៉ៃលិន, ប៉ៃលិន

ភូមិអូរតាពុកលើ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
ទូរសព្ទ: 069 666 064
អ៊ីម៉ែល: bm.pln@hkl.com.kh

## ៥០ សាខាមោងឫស្សី, បាត់ដំបង

ផ្លូវជាតិលេខ៥ ភូមិគារ៣ ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង
ទូរសព្ទ: 069 333 979
អ៊ីម៉ែល: mrs.bm@hkl.com.kh

# យើងខ្ញុំរង់ចាំបំរើលោកអ្នកគ្រប់ពេលវេលា

សំរាប់ព័ត៌មានបន្ថែម និងមតិកែលម្អសូមទំនាក់ទំនង

**023 999 266**

**ការិយាល័យកណ្តាល-រាជធានីភ្នំពេញ**

អគារលេខ 606 ផ្លូវលេខ271 សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន
រាជធានីភ្នំពេញ ទូរស័ព្ទ: 023 994 304 / 023 224 102
អ៊ីម៉ែល info@hkl.com.kh គេហទំព័រ www.hkl.com.kh



**ការិយាល័យកណ្តាល - ភ្នំពេញ**

អគារលេខ៦០៦ ផ្លូវលេខ២៧១ ភូមិ៦ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រ: ២០៤៤ ភ្នំពេញ៣
ទូរសព្ទ: ០២៣ ៩៩៤ ៣០៤ / ០២៣ ២២៤ ១០២
អ៊ីមែល: info@hkl.com.kh
គេហទំព័រ: www.hkl.com.kh